# មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI0109**

## សម្ភាសន៍ជាមួយឈ្មោះ យឿន ចែវ ភេទប្រុស អាយុ៥៨ឆ្នាំ
## មុខងារនៅសម័យខ្មែរក្រហម: ប្រធានកងយុវជនឃុំ
## មុខងារបច្ចុប្បន្ន: ក្រុមប្រឹក្សាឃុំថ្មពួក
## សព្វថ្ងៃរស់នៅភូមិស្វាយ ឃុំថ្មពួក ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ
## ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១០
## សម្ភាសន៍ដោយ: ហ៊ិន សុធានី
## ០១:២៩:២៨
## ៦២ទំព័រ

ធានី : ថ្ងៃហ្នឹងថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១០ ។ ខ្ញុំមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយខ្ញុំចុះមកនេះគ្រាន់តែចង់សាកសួរពីប្រវត្តរបស់ពូ ដែលពូបានឆ្លងកាត់តាំងពីក្មេងរហូតមកដល់ឥឡូវ ដែលពូបានធ្វើការអីខ្លះ ហើយជួបប្រទះរឿងអីខ្លះចឹង ។

ចែវ : បាទៗ ។

ធានី : ហើយរឿងរ៉ាវដែលពូកពូ ប្រាប់ពួកខ្ញុំៗសុំអនុញ្ញាតិសម្រាប់យកទៅធ្វើជាសៀវភៅក៏ដូចជាសម្រាប់អ្នកស្រាវជ្រាវ ឬក្មេងៗក្រោយៗបានរៀនស្រាវជ្រាវពីប្រវត្តរបស់ពូ ដូចថាពីប្រវត្តិកាលសម័យហ្នឹងយ៉ាងម៉េចៗចឹងណាពូណា ។

ចែវ : បាទ! អាចប្រាប់បាន ។

ធានី : ចឹងពូខ្ញុំសុំថតជាសម្លេង ក៏ដូចជាថតជារូបអីបានទេ?

ចែវ : បាន ។

ធានី : ពូមានឈ្មោះអីគេ?

ចែវ : បាទ! ខ្ញុំឈ្មោះ យឿន ចែវ ។

ធានី : យឿន ចែវ?

ចែវ : ចែ ។

ធានី : នឹង វ ពូនោះ?

ចែវ : បាទៗ ។

ធានី : ឆ្នាំនឹងពូអាយុប៉ុន្មានហើយ?

ចែវ : ឆ្នាំសព្វថ្ងៃនេះ?

ធានី ៖ ចាំ!

ថៃវ ៖ អាយុ៥៨ឆ្នាំ ។

ធានី ៖ អាយុ៥៨ ។ ពូមានស្រុកកំណើតនៅណាវិញ?

ថៃវ ៖ នៅភូមិស្វាយ ឃុំថ្មពួក ស្រុកថ្មពួក ។

ធានី ៖ ភូមិស្វាយ ឃុំថ្មពួក?

ថៃវ ៖ ឃុំថ្មពួក ស្រុកថ្មពួក ។

ធានី ៖ ថ្មពួក ខេត្ត?

ថៃវ ៖ ខេត្តបាត់ដំបងសម័យនោះ ។

ធានី ៖ ដល់ពេលឥឡូវ?

ថៃវ ៖ ខេត្តបន្ទាយមានជ័យ បច្ចុប្បន្នបន្ទាយមានជ័យ ។

ធានី ៖ ចឹងកាលមុនបាត់ដំបងទេ?

ថៃវ ៖ បាទ! កាលមុនបាត់ដំបង ។

ធានី ៖ តែឥឡូវពូមានស្រុកកំណើតនៅភូមិស្វាយនឹងដដែរ?

ថៃវ ៖ ភូមិស្វាយ បាទ! ដដែល ។

ធានី ៖ ឪពុកពូឈ្មោះអីគេ?

ថៃវ ៖ ឪពុកឈ្មោះ យាត យឿង ។

ធានី ៖ យាត យឿង?

ថៃវ ៖ បាទ!

ធានី ៖ គាត់ស្លាប់ហើយ?

ថៃវ ៖ គាត់ស្លាប់ហើយ ។

ធានី ៖ ស្លាប់ពេលណាដែរពូ?

ថៃវ ៖ ស្លាប់ប្រហែលជា ជាង១០ឆ្នាំ ។

ធានី ៖ ស្លាប់ជាង១០ឆ្នាំ?

ថៃវ ៖ ឆ្នាំដែរ ឆ្នាំអឺ!៨០ អឺ!៩៧ គាត់ស្លាប់ឆ្នាំ១៩៩៧ ។

ធានី ៖ ១៩៩៧?

ថៃវ ៖ ហ្នឹង ។

ធានី ៖ ដោយសារអីដែរពូ?

ថែវ ៖ គាត់ដាច់ជើង ។

ធានី ៖ ដាច់ជើង ពិការ ជាន់មីន?

ថែវ ៖ ពិការជើង បាទ! ជាន់មីនៗខ្មែរក្រហម អឺ!ជាន់មីនយួន ។

ធានី ៖ មីនយួន ។ នៅណាវិញ?

ថែវ ៖ កាលដែលយួនវាវាយបោះជំរំនៅប្រាសាទយើងនេះ វាដាក់មីនការពារកន្លែងវា ដល់យើងទៅស្រែ យើងដើរលើក្លឹទៅជាន់មីនវា ។

ធានី ៖ នៅភូមិយើងដែរ?

ថែវ ៖ នៅភូមិយើងដែរ នៅភូមិស្វាយ ខាងកើតភូមិស្វាយ នៅខាងកើតភូមិ ។

ធានី ៖ ចុះម្ដាយពូឈ្មោះអីគេ?

ថែវ ៖ ឈ្មោះ ហំ វុធ ។

ធានី ៖ ហំ វុធ?

ថែវ ៖ បាទ!

ធានី ៖ គាត់នៅរស់ទេ?

ថែវ ៖ នៅរស់ ។

ធានី ៖ បងប្អូនពូប៉ុន្មាននាក់?

ថែវ ៖ បងប្អូនខ្ញុំ៦នាក់ ។

ធានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ថែវ ៖ ស្រី១ ប្រុស៥ ។

ធានី ៖ អត់មានបាត់បង់ណាបងប្អូនពូ?

ថែវ ៖ ស្លាប់ម្នាក់នៅ អឺ!ស្លាប់២ ។

ធានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន២នាក់នឹង?

ថែវ ៖ ស្លាប់ប្រុស២ ។

ធានី ៖ ដោយសារអីគេពូ?

ថែវ ៖ ដោយសារនែក! ១ធ្វើប៉ាវ៉ាវៃជំរំពិល ។

ធានី ៖ ១ធ្វើជាទាហានប៉ាវ៉ា?

ថែវ ៖ បាទ! នៅជំរំពិល វៃជំរំពិលទៅស្លាប់ យួនវៃជំរំពិល ។

ធានី ៖ មួយទៀត?

ថែវ ៖ មួយទៀតទៅដេកនៅសំរោងក្នុងព្រៃ គេឆ្លុះទៅឆ្លួលទៅឃើញស្នាន់តែឃើញភ្នែកភ្លែ បាញ់ភ្លែ ទៅក៏ត្រូវមនុស្សស្លាប់ ។

ធានី ៖ មួយទៀតដេកក្នុងព្រៃបាញ់ស្លាប់?

ថែវ ៖ បាទ!

ធានី ៖ ប៉ុន្តែសម័យ ឆ្នាំប៉ុន្មាន ពូចាំទេ?

ថែវ ៖ ឆ្នាំ៨៤ ។

ធានី ៖ ទាំង២នាក់ហ្នឹង?

ថែវ ៖ បាទ! យ៉ាងណាក៏៨៤គ្នា ។

ធានី ៖ និយាយទៅ៨៤ទាំងពីរ?

ថែវ ៖ បាទ! ទាំងពីរ សម័យវៃជំរំពិលក៏៨៤ ។

ធានី ៖ ចាំ! ពូរៀនបានដល់ថ្នាក់ទីប៉ុន្មានដែរ?

ថែវ ៖ ខ្ញុំរៀនថ្នាក់ទី៨ ។

ធានី ៖ រៀនថ្នាក់ទី៨នៅសាលាណា?

ថែវ ៖ ទី៨នៅសាលាថ្មពួក ។

ធានី ៖ សាលាថ្មពួក ៨ចាស់ ៨ថ្មី?

ថែវ ៖ ៨សម័យមុន សម័យលន់ នល់ ។

ធានី ៖ ថ្នាក់វិទ្យាល័យ?

ថែវ ៖ ៨ចាស់ទៀត បើយើងរាប់កាលមុនវាទី១២ ។

ធានី ៖ ហ្នឹងហើយបឋមសិក្សា១២ ១១ ១០ ។

ថែវ ៖ ១១ ១០បាទ! ចុះមកក្រោម ។

ធានី ៖ ពូរៀបគ្រួសារឆ្នាំណា?

ថែវ ៖ ខ្ញុំរៀបនៅរបបប៉ុលពត ឆ្នាំ៧៦ ។

ធានី ៖ គ្រួសារពូឈ្មោះអីគេ?

ថែវ ៖ ឈ្មោះ ដាដា ។

ធានី ៖ ឈ្មោះ ដាដា?

ថែវ ៖ បាទ! ដាដា ។

ធានី ៖ ពិរោះណាស់ ។

ថែវ ៖ រស់ ។

ធានី ៖ ផាផា ឈ្មោះគាត់ពិរោះ?

ថែវ ៖ នោះហើយពិរោះ ។

ធានី ៖ ពូមានកូនប៉ុន្មាននាក់ហើយ?

ថែវ ៖ ខ្ញុំមានកូន៤នាក់ ។

ធានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ថែវ ៖ ស្រី១ ប្រុស៣ ។

ធានី ៖ ចង់ឲ្យពូរៀបរាប់ប្រវត្តិពីដំបូង ដូចថាតាំងពីពេលពូចូលរៀនរហូតដល់ពេលឈប់រៀន?

ថែវ ៖ បាទ! ចាំមើលខ្ញុំនិយាយពីប្រវត្តិណា ក្រោយមកគឺខ្ញុំបានចូលរៀនចេញពីរៀនគ្រូស យើងរៀនអាយុធំហើយ ដល់កាលខ្ញុំរៀនអាយុ១២ឆ្នាំ ។ ដល់១២ឆ្នាំចន្លោះ១៦ឆ្នាំ ខ្ញុំបួសៗនៅវត្តថ្មពួក ។

ធានី ៖ អាយុ១៦ឆ្នាំ?

ថែវ ៖ បាទ! បានបួសនៅវត្តថ្មពួក ។

ធានី ៖ ម៉េចទៀតពូ?

ថែវ ៖ ក្រោយមកគឺខ្ញុំបួស ក្រោយមកលោកក្នុងចំណុះវត្ត១០០អង្គ ស្រាប់តែពេលរំដោះឆ្នាំ៧៥ មកប៉ុលពតគេផ្សឹក គេឲ្យលោកចិញ្ចឹមជ្រូក ឲ្យលោកចិញ្ចឹមជ្រូក ឲ្យលោកចិញ្ចឹមទា ឲ្យលោកចិញ្ចឹមមាន់ ។ ដូច្នេះក្នុងចន្លោះនោះ ខ្ញុំៗព័ទ្ធទំនប់ទៅនៅតាខ្ញុំនៅព្រៃ គាត់ធ្វើខ្ទមនៅព្រៃឡើង៣អង្គទៅនៅទៅពួនៗថាមិនព្រមសឹក ។ ដល់ស្រាប់មកវិញ លោកសឹកអស់រលីងម៉ាវត្តនៅសល់តែចៅអធិការ៤អង្គ ។

ធានី ៖ និងលោកពូដែរ?

ថែវ ៖ បាទ! លោកតាមេគុណ លោកតាអនុគុណ ហើយនឹងលោកតាចាស់មួយទៀត នៅសល់៣អង្គគត់ ។

ធានី ៖ និងលោកពូដែរ?

ថែវ ៖ ខ្ញុំ នៅ៣អង្គពេលនឹង ។

ធានី ៖ លោកពូជាព្រះសង្ឃដែរ?

ថែវ ៖ ព្រះសង្ឃដែរ រត់ចេញទៅ ដល់មកវិញឃើញលោកតាយំថាសឹកចោលអស់ កាលនោះគេសឹកអស់រលើងមែន ក្រោយមកខ្ញុំនៅចាំវស្សាដល់បិណ្ឌៗ ប៉ុលពតវារកលេសមិនបានឲ្យ ខ្ញុំ

សឹក មកឲ្យលោកតាបានសឹក វាយកកាំភ្លើងទៅសឹកក្រោមទូៗ ។ ដល់ក្រោយមកវាឡើងទៅលេងជាមួយលោកឪលោកតាមេគុណលោកតា ឌឹម អឹក វត្តថ្មពួកនេះ ដល់វាឃើញកាំភ្លើងថាលោកមានកាំភ្លើង ។ ដូច្នេះវាជម្លៀសយើងទាំង៦អង្គ នោះទៅសឹកនៅវត្តគោកខ្ពស់ យើងក្នុងព្រៃនោះ ។ វត្តគោកខ្ពស់យើង ឃុំថ្មី ។ ដល់សឹកយើង វាជម្លៀសលោកទាំងអស់ពីស្វាយចេក សរុបទាំងអស់លោកជាង១០០អង្គសឹកចោលៗទាំងអស់ ខ្ញុំមកវិញ មកអត់ទេ គ្មានអីស្លៀកស្បង់យើងកាត់ស្បង់សនេះធ្វើខោរឹតៗ ។ មកដល់ភូមិៗ គេបំពាក់ខ្ញុំឲ្យទៅជា សក់ត្រងោលមិនទាន់ដុះផងនោះ ។ ឲ្យទៅជាប្រធានយុវជន ក្តោបក្តាប់យុវជន គេថាយើងប្រវត្តិរូបល្អ គេថាយើងអ្នកសឹកថ្មី ប្រវត្តិរូបល្អមិនបានបម្រើនិន្នការសក្តិភូមិ គេឲ្យយើងធ្វើ មេដឹកនាំ ។ ខ្ញុំក៏ធ្វើមេដឹកនាំ ក្នុងនាមជាប្រធានយុវជនសម្រាប់ដឹកនាំចល័តបិទភ្លឺបិទប្រឡាយ ទាំងយប់ទាំងថ្ងៃ ។ នាំកម្លាំងធ្វើទាំងយប់ទាំងថ្ងៃ បិទភ្លឺ ដាក់ភ្លឺអាគុយត្រូវមានភ្លឺម៉ាស៊ីនចាស់ មួយគេដាក់ភ្លឺ២-៣អំពូល បិទភ្លឺទាំងយប់ទាំងថ្ងៃទៅ ។ ក្រោយមកទៀត ឆ្នាំ៧៦ គេឲ្យខ្ញុំទៅបិទអាងត្រពាំងថ្ម នាំកម្លាំងយុវជន យុវនារីទៅបិទអាង ត្រពាំងថ្មនៅឆ្នាំ៧៦ ។ ហើយបានបិទអាងចប់សព្វគ្រប់ បានដឹកព្រែកចេញពីអាងស្ពានទី១ទៅព្រៃមាន់ ហើយទៅបោះទីតាំងនៅគេហៅជំរំហៅការដ្ឋានគល់រំចេក គេក៏រើសគូស្រករមេៗថ្នាក់ដឹកនាំ មេកងតូច មេកងធំ កងពិសេសហ្នឹង គេឲ្យយើងមានគ្រួសារ គណៈតំបន់ អៀង ឡៃ ឈ្មោះវាអៀង ឡៃ ប្រធានតំបន់៧៥ ។ ឲ្យយើងរៀបការ៥៥គូ ម៉ាវគ្គនោះគេរៀប៥៥គូនៅក្នុងចន្លោះឆ្នាំ អឺ! ១៩៧៦ ចូលដិត៧៧ បានរៀបការ ។ ហើយខ្ញុំរៀបការទៅគេខ្ញុំទៅបូតស្រូវៗគេចាប់ខ្ញុំ ដាក់ថាធ្វើទោស១ខែនៅគេហៅឃុំទឹកដោរ ។ គេបញ្ជូនខ្ញុំទៅនៅឃុំទឹកដោរប្រុងសម្លាប់ដែរ ប៉ុន្តែដូចបែជន្យខ្ញុំអាយុវែង គេចងបណ្តើរទាំងយប់ ប៉ុន្តែវាសនាខ្ញុំដូចថាទឹកដោះម្តាយថ្ងៃទៅបានរស់ គេប្រុងនឹងវ៉ៃចោលដែរ សំណាងដែលដូចម៉េចវាទុកចោលទុកឲ្យខ្ញុំកសាងដីកក្នុងដីម៉ាម៉ែត្រគីបឲ្យជីក អឺ!នែក!លុតដំយើងក្នុងម៉ាថ្ងៃធ្វើម៉េចឲ្យបាន៥ម៉ែត្រគីបជីកឲ្យរួចឲ្យគេ បើជីករួចរស់ ខ្ញុំខំតស៊ូត្រដរធ្វើម៉េចឲ្យបានរួចផុតពីសេចក្តីស្លាប់ក៏លើកដីបាននឹងដូចបំណងរបស់ខ្ញុំ រាល់ថ្ងៃ គេពិសោធន៍ខ្ញុំ១០ថ្ងៃៗគឺឲ្យបានក្នុងម៉ាថ្ងៃឲ្យបាន៥ម៉ែត្រគីប ជីកបាន១០ថ្ងៃចប់ដូច ថាយើងលុតពលកម្មបានគេបន្ធូរយើង គេឲ្យយើងទៅបញ្ជាន់ស្រូវនៅភូមិភ្នំលាបៗក្នុងស្រុក អឺ! ស្ថិតនៅ ។

ធានី : ព្រះនេត្រព្រះ?

ថែវ ៖ ស្រុកព្រះនេត្រព្រះឲ្យយើងទៅបញ្ជាន់ស្រូវ ។ ក្រោយមកគេដឹងថាយើងលុតពលកម្មល្អបាន ល្អទៅ គេឲ្យមេខ្ញុំខាងតំបន់៥ គណៈតំបន់យើងខាងតំបន់គេឲ្យទៅយកខ្ញុំមកវិញ ។ យកមក វិញស្រាប់តែយកមកវិញហ្នឹង ។

ធានី ៖ ឈ្មោះ អៀង ឡៃនឹងពូ គណៈតំបន់៥ ?

ថែវ ៖ អៀង ឡៃ បាទ! អៀង ឡៃ គណៈតំបន់ ។

ធានី ៖ ម៉េចពូ?

ថែវ ៖ ដល់មេគេស្រាប់ឲ្យខ្ញុំមកនៅកន្លែងវិញៗ ខ្ញុំនៅបានប្រហែលជា ខ្ញុំធាត់ធំវិញ ប្រហែលជា បើគិតទៅ៣ខែ ៤ខែ គេឲ្យបាយស៊ីពេញមាត់ពេញកទៅឆ្អែត បានធាត់ធំវិញ ។ ខ្ញុំរត់ពីការ ដ្ឋាននោះ នាំប្រពន្ធខ្ញុំរត់ ១៥គ្រួសារជំរំការដ្ឋានរំបេកនោះមកស្រុកវិញ ។ មកភូមិកំណើត របស់ខ្លួនវិញ ។ ដល់មកភូមិកំណើតរបស់ខ្ញុំវិញ ខ្ញុំរត់ម៉ោយប់ភ្លឺមកដល់ផ្ទះតែម្ដង អត់មានចាប់ ខ្ញុំបានទេ ។ ដល់ផ្ទះស្រាប់តែដល់ភូមិខ្ញុំនេះ មានហៅថាប្រធានសហករណ៍គេៗ បំពាក់ឲ្យខ្ញុំធ្វើ មេក្រុមបាយទៀត ខ្ញុំមិនដែលមានតួចទេទៅរហូត ។ ធ្វើមេក្រុមបាយៗ មេ ក្រុមទី៧ ។ ដល់មេក្រុមទី៧ ស្រាប់តែពេលនោះ គេឲ្យខ្ញុំជ្រើសរើស មើលគេមានឈ្មោះ មួយ គេឲ្យយើងមកប្រជុំៗ ហើយមើលបញ្ជីឈ្មោះគេ ។ គេឲ្យយើងមើលមនុស្សណា ដែលត្រូវទៅជម្លៀស ទៅរៀនសូត្រផ្នែកកសិកម្មជាន់ខ្ពស់នៅខាងក្រោម ថ្នាក់ក្រោមបេះ ដឹងទៅណាទេ ដូចខាង ក្រោមបញ្ជូន ។ ក្នុងនោះគឺបញ្ជូនទៅជម្លៀស៤០គ្រួសារ គិតយក ទៅវៃចោលនៅសាលាកា លេះនេះ៤០គ្រួសារនឹង ។ ដល់ឲ្យខ្ញុំជ្រើសរើសក្នុងក្រុមខ្ញុំ អត់ មានអ្នកណាមួយអ្នកមាន ក្រុមណាមួយអត់មានឈ្មោះអ្នកណាមួយត្រូវជម្លៀសទៅមួយទេ មានតែក្រុមគេផ្សេង ព្រោះក្រុមខ្ញុំដឹងពីប្រវត្តិសុទ្ធតែប្រវត្តិល្អទទេរ ក្រុមទី៧ អត់មានអ្នក ណាត្រូវទៅជម្លៀសទេ ។ ដល់ពេលខ្ញុំមើលទៅអត់មានឈ្មោះ ខ្ញុំប្រាប់ទៅគណៈកងគេថា ខ្ញុំអត់មានទេគ្រួសារនៅក្នុងក្រុមខ្ញុំ អត់មានឈ្មោះណាត្រូវទៅជម្លៀសទេ ។ ដូច្នេះគេសួរថា ពិតមិនពិត? ថាពិត ព្រោះខ្ញុំអត់ មានគ្រួសារណាមួយដែលពាក់ព័ន្ធថា បម្រើការផារសក្ដិ ភូមិទេ ដូច្នេះក៏ខ្ញុំប្រាប់គេត្រង់ទៅក៏គេអត់រករឿងឲ្យយើងឆ្លើយត្រង់ ប្រាប់ឲ្យគេត្រង់ថាមែន ដល់ពេលនេះទៅ ក្រុមខ្ញុំអត់មានខាត មនុស្សមួយទេ បើក្រៅពីនឹងខាត ។ គេយកជម្លៀស គេយកទៅវៃចោលនៅសាលាកាលេះ អស់៤០គ្រួសារ អត់មានកំហុសអីសោះ ។ ហើយខ្ញុំដឹងថាពួកអ្នកទាំងនោះស្លាប់ក្នុងយប់នោះខ្ញុំរត់ទៅថៃ រត់ទៅជ្រកនៅស្រុកថៃ អត់បាន លាប្រពន្ធម៉ាមាត់ ហើយប្រពន្ធអត់ដឹងខ្លួន ទៀត ។ ទៅដល់ដោយគិតគ្នាឯងចំនួន២៥នាក់

នាំគ្នារត់ទៅថៃ រត់ដល់ថៃៗគេធ្វើបាប គេចង់ព័ទ្ធស្លាបសេក គេធាត់ គេយកដាវយកអីមក ចាក់យើងតិចៗឲ្យយើងភ័យខ្លាចគេគំរាមឲ្យ យើងរត់ទៅវិញ ។ ខ្ញុំថាបើរត់ទៅវិញ ខ្មែរក្រហមសម្លាប់ចោលហើយ សុខចិត្តឲ្យថៃស្លាប់ចុះ គេពិសោធន៍យើងណា រយៈពេលហ្នឹងខ្ញុំរស់នៅជាមួយគេបានរហូតដល់ឆ្នាំ៨០ ខ្ញុំត្រឡប់មក ដូចថាឯនេះរំដោះបានខ្ញុំរស់នៅភូមិកំណើតរបស់ខ្ញុំ ។ ឆ្នាំ៨០ ខាងរដ្ឋកម្ពុជាហៅថាហេង សំរិន ខាងទ័ពហេង សំរិន គេឲ្យខ្ញុំធ្វើមេភូមិ ។ មកដល់ធ្វើមេភូមិទៀត នេះប្រវត្តិខ្ញុំ ។

ធានី ៖ មេភូមិអីគេពូ?

ថៃវ ៖ មេភូមិស្វាយយើងនេះឯង ។

ធានី ៖ ចាំ! ម៉េចទៀត?

ថៃវ ៖ ឲ្យខ្ញុំធ្វើជាមេភូមិដឹកនាំបងប្អូនក្នុងស្រុកក្នុងស្រែទៅ ក៏បានសុខសាន្តមិនដែលមានបានមកចាប់មកចងខ្ញុំទេ ហើយបើក្រៅពីនឹង មានអាក្រោមខ្ញុំ មានចាប់ដាក់គុកធ្វើខុស ចាប់ដាក់គុក ប៉ុន្តែខ្ញុំមិនដែលធ្វើខុសទេ ។ ខ្ញុំរែកៗម៉េចក៏ខ្ញុំរែក ទ័ពព្រៃក៏ខ្ញុំជួយ ទ័ពខាងណាក៏ខ្ញុំជួយ មានអង្ករមានអីរែបងប្អូនឲ្យរស់ទាំងអស់គ្នា បានខ្ញុំអត់ប្រកាន់និន្នាការអី ដូច្នេះបានខ្ញុំរស់បែបនោះឯងរស់ត្រង់ដែលខ្ញុំចេះមានគំនិតមួយរែក មិនហៅថាដើម្បីខ្មែរដូចគ្នា បើថាទ័ពព្រៃខាងប៉ាវ៉ាមកក៏ ខ្ញុំរាយអង្ករឲ្យ ទ័ពខ្មែរក្រហមមកក៏ខ្ញុំរាយការណ៍ឲ្យ ទ័ពខាងក្នុងថាខ្ញុំថាទេ រឿងខ្ញុំត្រូវតែរាយ បើមិនមានអ្នកណាការពារខ្ញុំ បើខ្ញុំមិនរាយឲ្យគេៗសម្លាប់ខ្ញុំចោល ។

ធានី ៖ រាយការណ៍ពូ?

ថៃវ ៖ រាយអង្ករឲ្យគេ រាយអង្ករឲ្យទ័ព រាយបងប្អូនតាមផ្ទះ បើទ័ពគេខ្វះអង្ករស៊ី គេសុំពឹងដល់មេភូមិ ឲ្យមេភូមិរាយអង្ករឲ្យគេ ខ្ញុំក៏រាយអង្ករឲ្យគេទៅ បើខាងក្នុងវាថា ចុះម៉េចក៏រាយអង្ករ? ទេ! ចុះបើខ្ញុំមិនរាយគេសម្លាប់ខ្ញុំចោល គេយកគោក្របីខ្ញុំ ។ ដូច្នេះគ្មានអ្នកណាការពារខ្ញុំដើម្បីខ្ញុំការពារ ដើម្បីសន្តិសុខ ខ្ញុំសុខ គឺខ្ញុំត្រូវតែចែកគេស៊ីខ្លះ បើសិនជាខ្ញុំរស់នៅដោយសន្តិភាព រស់ដោយសន្តិសុខ ខ្ញុំមិនហ៊ានដែលទៅរាយឲ្យខ្មាំងធ្វើអីនោះទេ ។ ដូច្នេះដើម្បីខ្ញុំរស់ ក៏បើខ្ញុំថាត្រូវទៅ គេអត់ហ៊ានថាវិញទេ ។ ក្រោយមកទៀត ក៏ឲ្យខ្ញុំឡើងមកធ្វើនគរបាលឃុំៗដល់ក្រោយរំដោះឆ្នាំ ក្នុងចន្លោះឆ្នាំ៩០ ៩១ ដែលយួនថយស្រុកទៅវិញ ខ្ញុំក៏ឈប់ធ្វើការត្រឹមនោះឯង ឈប់ធ្វើការ ។ ក្រោយមកទៀត បានខ្ញុំធ្វើជាបេក្ខជនឈរឈ្មោះខាងក្រុមប្រឹក្សាឃុំ បានជាប់ក្រុមប្រឹក្សាឃុំ២អាណត្តិមកដល់សព្វថ្ងៃនេះ ។

ធានី ៖ ចឹងពូធ្វើក្រុមប្រឹក្សាឃុំ រាល់ថ្ងៃនឹង?

ថែវ : បាទ!

ធានី : ក្រុមប្រឹក្សាឃុំថ្មពួកហ្នឹង?

ថែវ : បាទ! ថ្មពួក ។

ធានី : ចឹងដំបូងពូនៅខាងនគរបាលឃុំថ្មពួកដែរ?

ថែវ : បាទ! ពីសម័យរដ្ឋកម្ពុជា ។

ធានី : ឆ្នាំប៉ុន្មានសម័យរដ្ឋកម្ពុជា?

ថែវ : ឆ្នាំដែលខ្ញុំធ្វើនរគបាល ។

ធានី : ចា៎!

ថែវ : ឆ្នាំ ៨៨ ៨៩ ធ្វើបានម៉ាឆ្នាំជាង ។

ធានី : ដល់ពេលហើយឆ្នាំប៉ុន្មាន ដែលពូឈរឈ្មោះធ្វើជាបេក្ខជន?

ថែវ : ដែលឆ្នាំ ឈរបេក្ខជនឆ្នាំ៩០ៗ អឺ!២០០០ ។

ធានី : ថា៩០ ៩១ដ ពូធ្វើអីគេ?

ថែវ : ៩០ ៩១ខ្ញុំសម្រាក អត់បានធ្វើអីទេ ធ្វើអ្នកស្រុកធម្មតាឈប់ អត់បានទេ ។

ធានី : ៩១ ប្រជាជន?

ថែវ : ប្រជាជនធម្មតា ។

ធានី : ចុះដល់ពេល២០០០?

ថែវ : ២០០២ឈរជាបេក្ខជនឃុំ ។

ធានី : ជាប់ជាបេក្ខជនឃុំ?

ថែវ : បាទ! ជាប់បេក្ខជនឃុំ ។

ធានី : ជាប់សមាជិកឃុំ?

ថែវ : សមាជិកឃុំ សមាជិកក្រុមប្រឹក្សាឃុំ ។

ធានី : សមាជិកក្រុមប្រឹក្សាឃុំ?

ថែវ : បាទ!

ធានី : ឃុំថ្មពួក ដល់បន្ទាប់មទៀត?

ថែវ : ដល់បោះឆ្នោត២០០៧ ជាក្រុមប្រឹក្សាឃុំទៀត ។

ធានី : នៅក្រុមប្រឹក្សាឃុំដដែល?

ថែវ : បាទ! ជាប់មកទៀតដដែល ។

ធានី ៖ ដល់រាល់ថ្ងៃ?

ថៃវ ៖ បាទ! រាល់ថ្ងៃ ។

ធានី ៖ ចឹងពូ ខ្ញុំសុំបកក្រោយតិច កន្លែងដែលពូនិយាយថា ពូបានបួសជាព្រះសង្ឃ ពូបានបួសជាព្រះសង្ឃបួសអាយុ១៦ឆ្នាំ?

ថៃវ ៖ បាទ! អាយុ១៦ឆ្នាំ ។

ធានី ៖ រហូតដល់អាយុប៉ុន្មាន បានពូសឹក?

ថៃវ ៖ ខ្ញុំសឹកនៅឆ្នាំ សឹកដែលពួករំដោះវាសឹកចោលនៅឆ្នាំ៧៥ ។

ធានី ៖ ចឹងនៅឆ្នាំ១៩៧៥ម៉ង?

ថៃវ ៖ បាទ!

ធានី ៖ ចឹងនៅឆ្នាំ១៩៧៥ម៉ង បានផ្សឹក?

ថៃវ ៖ បានសឹក ។

ធានី ៖ សឹកពីព្រះសង្ឃ?

ថៃវ ៖ បាទ!

ធានី ៖ ចឹងពូថា មានព្រះសង្ឃ៣នាក់ទៀត ដែលរត់ទៅក្នុងព្រៃនឹង មានអ្នកណាគេខ្លះលោកពូចាំឈ្មោះ បួននាក់លោកពូ?

ថៃវ ៖ នែក! ចាំៗ ។

ធានី ៖ ចា៎! ឈ្មោះអីខ្លះ?

ថៃវ ៖ បាទ! ខ្ញុំមួយ ពេជ ពិល មួយទៀត ។

ធានី ៖ ពេជ ពិល?

ថៃវ ៖ ពេជ ពិល ។

ធានី ៖ អ្នកណាគេទៀត?

ថៃវ ៖ គេជម្លៀសយកទៅវៃចោលហើយ ជម្លៀសវៃចោល ជម្លៀសសម័យនោះឯង ។

ធានី ៖ ចឹងដំបូងពូហើយ ពេជ ពិល ហើយអ្នកណាគេទៀត ២នាក់ទៀត?

ថៃវ ៖ ភិន ផល ភិន ។

ធានី ៖ ផល ភិន ហើយម្នាក់ទៀត?

ថៃវ ៖ ស្អីៗចយទេ ឪវាឈ្មោះ វាឈ្មោះចយ ជីងឪវាឈ្មោះស្អីទេ វាស្រុកចំណូល ។ ឈ្មោះចយ ប៉ុន្តែឪវាឈ្មោះអី វាក្មេងឈ្មោះតានោះកើត ដាក់តែឈ្មោះចយបានហើយ មួយទៀត ឈ្មោះចយ ។

ធានី ៖ ចុះពូថាលោកតាចាស់មួយណា ដែលសរសេរ?

ថៃវ ៖ តាចាស់ដែលស្លាប់ ។

ធានី ៖ ឈ្មោះអីគេ?

ថៃវ ៖ លោកតាមេគុណ ឪ អើយ ។

ធានី ៖ ចឹងបានន័យថា៤អង្គហ្នឹងស្របាលៗពូទេ ដែលរត់ចូលព្រៃ?

ថៃវ ៖ ៤អង្គដែលរត់ចូលព្រៃគឺក្មេងៗ ។

ធានី ៖ ក្មេងៗ?

ថៃវ ៖ បាទ! សុទ្ធតែក្មេងៗទាំងអស់គ្នា សុទ្ធតែក្មេងៗ ។

ធានី ៖ រត់ចូលព្រៃ ដល់ពេលរត់ចេញពីព្រៃវិញ?

ថៃវ ៖ មករកវត្តវិញ ។

ធានី ៖ មករកវត្តឃើញ?

ថៃវ ៖ ឃើញព្រះអង្គ៣អង្គៗនៅតែអង្គតែមួយនៅតាចាស់ៗទាំងអស់ ។

ធានី ៖ តែអត់ទាន់សឹកទេ?

ថៃវ ៖ អត់សឹកទេ ក្រៅពីនឹងលោកសឹកអស់រលីង ក្អែកយំកាក ពេញវត្ត ។

ធានី ៖ ពេញវត្ត?

ថៃវ ៖ ទេ! ពេញវត្ត មានតែសត្វក្អែកយំស្វាត់ជ្រាប គ្មានអ្នកណាទៅបៀតវត្ត ។

ធានី ៖ ចុះដែលថាមានព្រះសង្ឃមានតែ៣អង្គ?

ថៃវ ៖ ៣អង្គ កុដិធំៗណាស់ ពីដើមកុដិថ្មពួកធំៗ ។

ធានី ៖ នៅវត្តណា?

ថៃវ ៖ វត្តថ្មពួក ។

ធានី ៖ ចឹងគេជគុណ៣អង្គនៅនឹង គេជគុណឈ្មោះអីខ្លះ លោកគេជគុណមេគុណ?

ថៃវ ៖ លោកគេជគុណមេគុណ ឪ អើយ ។

ធានី ៖ មេគុណ ឪ អើយ?

ថៃវ ៖ ឪ អើយ ។

ធានី ៖ ហើយអ្នកណាគេទៀត?

ចែវ ៖ មួយទៀត ទេព ប៊ុយ ។

ធានី ៖ ជាអីគេ?

ចែវ ៖ ខាងអនុ គេហៅបើយើងថាអនុ ។

ធានី ៖ អនុគុណ?

ចែវ ៖ អនុគុណ ទេ!គេហៅចឹងឯង ។

ធានី ៖ អនុគុណ?

ចែវ ៖ បាទ!

ធានី ៖ រង?

ចែវ ៖ បាទ! រងៗ ។

ធានី ៖ អនុគុណហើយម្នាក់ទៀត?

ចែវ ៖ តាទៀត លោកតាចំណូលឈ្មោះខ្ញុំភ្លេចហើយ លោកតាវត្តមកពីឆ្ងាយ គាត់មកស្នាក់នៅអ្នក ចំណូលលោកតាចាស់ ។

ធានី ៖ អត់ចាំទេ?

ចែវ ៖ អត់ចាំឈ្មោះ ។

ធានី ៖ ចា៎! ព្រះសង្ឃចំនួល?

ចែវ ៖ បាទ! ភ្លេចឈ្មោះ ដែលយូរនោះពេកទាំងអស់៦អង្គ ។

ធានី ៖ គាត់អាយុប៉ុន្មានប្រហែល លោកតាដែលមកស្នាក់?

ចែវ ៖ លោកតាដែលស្នាក់នៅ ដែលថាមិនស្គាល់ឈ្មោះនឹង?

ធានី ៖ ចា៎!

ចែវ ៖ អាយុប្រហែលជាក្រោមលោកតាអនុគុណ ។

ធានី ៖ អាយុប៉ុន្មានទៅ?

ចែវ ៖ បើគិតទៅសម័យនោះ ប្រហែលគាត់អាយុខ្ទង់៥០លើស ។

ធានី ៖ តែកាលសម័យនឹងអាយុប្រហែលខ្ទង់?

ចែវ ៖ សម័យនោះ ដែលគាត់នៅ ប្រហែលអាយុ៥០ជាង ។

ធានី ៖ ៥០ជាង ៥៨?

ចែវ ៖ បាទ! ៥០ជាង ៥៨នោះឯង ។

ធានី ៖ ៥៨ ប្រហែលពូនោះ?

ចែវ ៖ បាទ!

ធានី ៖ ចឹងពេលដែលលោកពូមកនឹង ឃើញតែលោកតាពអន្ត?

ចែវ ៖ លោកតាពអន្ត ។

ធានី ៖ លោកតាពអន្តដែលនៅចាំវត្ត?

ចែវ ៖ បាទ!នៅចាំវត្ត នៅជាព្រះសង្ឃ ។

ធានី ៖ នៅចាំវត្តជាព្រះសង្ឃ?

ចែវ ៖ លោកតាយំហ៊ូ លោកតាមេគុណយំហ៊ូឃើញខ្ញុំ ឃើញលោកក្មេងៗមក ស្មានតែសឹកអស់រលីងហើយ ស្មានតែសឹកអស់រលីងហើយ ស្មានតែគេផ្សឹកចោលអស់ ។

ធានី ៖ ដល់ពេលលោកពូនៅបានប៉ុន្មាន បានគេចាប់ផ្តើមផ្សឹក?

ចែវ ៖ ខ្ញុំនៅបានរហូតដល់បិណ្ឌតូច ជិតដល់បិណ្ឌ គិតមើល ។

ធានី ៖ ចឹងប្រហែលជាអាចខ្មែរក្រហមរំដោះនឹង ៧៥ ខែមេសា?

ចែវ ៖ ៧៥ ក្នុងចន្លោះ៧៥ បើយើងគិតទៅក្នុងខែដែលគេត្រូវជម្លៀសឹកនឹង ប្រហែលជាខែ១៦ ។

ធានី ៖ ខែ៦?

ចែវ ៖ បាទ!

ធានី ៖ បិណ្ឌនៅ?

ចែវ ៖ បិណ្ឌហើយ ខែបិណ្ឌ ។

ធានី ៖ ខែបិណ្ឌ ខែ៩?

ចែវ ៖ អូ! ខែ៩ហើយនោះ ខែកញ្ញា បាទ! ខ្ញុំសឹកមុនបិណ្ឌធំ សឹកខែ៨ គេជម្លៀសទៅខែ៨ សឹកមុនបិណ្ឌ ។

ធានី ៖ ហើយអ្នកណាគេដែលចាប់ផ្តើមយកកាំភ្លើងយកទៅដាក់នៅខាងក្រោមកុដិ?

ចែវ ៖ យោធា ។

ធានី ៖ យោធា ចាំឈ្មោះគាត់ទេ?

ចែវ ៖ អត់ចាំទេ ខ្ញុំដឹងបើវាឡើងទៅខ្ញុំដេកយប់ ។

ធានី ៖ យោធាខ្មែរក្រហម?

ចែវ ៖ បាទ! យោធាខ្មែរក្រហម ។

ធានី ៖ ខ្មែរក្រហមលួចដាក់អីគេ?

ថែវ ៖ លួចដាក់អាវុធក្រោមទូ ។

ធានី ៖ ក្រោមទូព្រះសង្ឃ?

ថែវ ៖ ក្រោមទូៗចានឆ្នាំង ។

ធានី ៖ ទូចានឆ្នាំងរបស់ព្រះសង្ឃ?

ថែវ ៖ របស់ព្រះសង្ឃ ។

ធានី ៖ ដល់ពេលគេរកឃើញ គេធ្វើម៉េច?

ថែវ ៖ ដល់ពេលនោះវាឡើង ប៉ុននេះបាត់លោកៗតា វាធ្វើជាដើរនេះដើរនោះដើរដល់នោះទៅរក អាកាំភ្លើងនឹង វាសួរអាកាំភ្លើងនឹង កាំភ្លើងអ្នកណា ចោទថាលោកមានកាំភ្លើង ។

ធានី ៖ ហើយបន្ទាប់មកទៀតធ្វើម៉េច?

ថែវ ៖ បន្ទាប់មកទៀត វាក៏ចាប់ផ្តើមជម្លៀសលោកឲ្យទៅនៅគោកខ្ពស់ ។

ធានី ៖ លោកពូទៅដែរ?

ថែវ ៖ បាទ! ខ្ញុំទៅដែរ ខ្ញុំទៅទាំងអស់គ្នា ។

ធានី ៖ ទៅនៅគោកខ្ពស់?

ថែវ ៖ បាទ! ទៅនៅគោកខ្ពស់ វារកលេសដើម្បីឲ្យយើងសឹក ផ្សឹកយើងចោល វារកកំហុសវាមិន បាន ។

ធានី ៖ គោកខ្ពស់នឹងនៅខាងណាវិញ?

ថែវ ៖ គោកខ្ពស់នៅខាងត្បូងភូមិថ្មី ភូមិគោកខ្ពស់ ក្នុងព្រៃ ។

ធានី ៖ គោកខ្ពស់?

ថែវ ៖ បាទ!

ធានី ៖ ភូមិ ឬក៏ឃុំ?

ថែវ ៖ ភូមិគោកខ្ពស់ ប៉ុន្តែមិនមែនក្នុងភូមិទេ ទុកក្នុងព្រៃ ខាងកើតភូមិ ។

ធានី ៖ ក្នុងព្រៃខាងកើតភូមិ ក្នុងព្រៃ?

ថែវ ៖ បាទ! ដំណើរប្រុងនឹងវៃចោល មិនដឹងម៉េចៗ ដែលវាថ្មីៗពេកវាមិនទាន់វៃចោល ។

ធានី ៖ អូ! យកទៅវៃចោល យកទៅណាទៅ?

ថែវ ៖ យកទុកឲ្យយើងទុកក្នុងព្រៃ ឲ្យយើងរកបានសឹក គេថាឲ្យយើងសឹក បិទចរាចរណ៍វាបិទមិនឲ្យ មានអ្នកណាយកចង្ហាន់ចូលវត្តទេ វាឲ្យយើងអត់ចង្ហាន់ អត់បាយ ។

ធានី ៖ នៅក្នុងព្រៃ?

ថែវ ៖ បាទ! ឲ្យយើងសឹក ។

ធានី ៖ នៅប៉ុន្មានថ្ងៃ?

ថែវ ៖ ខ្ញុំនៅម៉ាអាទិត្យ ។

ធានី ៖ រយៈពេលមួយអាទិត្យ?

ថែវ ៖ បាទ!

ធានី ៖ រយៈពេលមួយអាទិត្យហើយ បានលោកពូសឹកខ្លួនឯង ឬមួយយ៉ាងម៉េច?

ថែវ ៖ សឹកទាំងអស់គ្នា អត់មានអ្នកណាសឹកអ្នកណាទេ គឺនាំគ្នាសឹក អត់មានអ្នកណាទៅបៀតវត្ត ។

ធានី ៖ ចឹងយើងអត់បានធ្វើតាមវិន័យលោក?

ថែវ ៖ អត់ធ្វើទេ អត់មានធ្វើតាមវិន័យកើតទេ សូត្រគ្នាឯង គិតសូត្រគ្នាឯង ខ្ញុំសូត្រឲ្យគ្នាឯងទៅ អ្នកដែលក្រោយអត់បានសូត្រ លោកឲ្យបានលោកតាពាអង្គនឹងសូត្រឲ្យ អ្នកដែលក្រោយបំផុត ។ លោកទាំងអស់១០០អង្គ ក្នុងម៉ាថ្ងៃសឹកអស់រលីង ។

ធានី ៖ ចឹងមិនមែនតែទៅតែ ពេលនឹងទៅតែលោកពូ?

ថែវ ៖ ទេ! លោកគ្រប់វត្តៗ គេដឹងថាលោកមេគុណ ចំនុះក្នុងមេគុណគេយកយើងលោកយកទៅ ប៉ុន្តែក្រោមអាដូចវត្តស្វាយចេក វត្តតាប៉ែន វត្តណាណៃចំណុះក្រោមមេគុណ គេហៅយកទៅទាំងអស់ ។

ធានី ៖ ហៅទៅទាំងអស់ ប៉ុន្តែដល់លោកតាដែលនៅវត្តលោកពូហ្នឹង មានតែ៤អង្គទេ ដែលមិនទាន់ទៅសឹក?

ថែវ ៖ បាទ! ដែលមិនទាន់បានទៅសឹក ។

ធានី ៖ ហើយប្រមូលគ្នាទៅផ្សេងៗ?

ថែវ ៖ បាទ! ប្រមូលគ្នាទៅជុំ ។

ធានី ៖ ទៅជុំទៅបានសឹក?

ថែវ ៖ រយៈពេលម៉ាអាទិត្យទៅជុំគ្នាទាំងអស់ ។

ធានី ៖ ហើយសឹកនៅនឹងជាង១០០?

ថែវ ៖ បាទ! សឹកទាំងអស់គ្នា ជាង១០០អង្គ ។

ធានី ៖ ដល់ពេលសឹកហើយម៉េចទៀតទៅ?

ថែវ ៖ សឹកហើយ គេឲ្យមកផ្ទះវិញ ។

ធានី ៖ ពូថាឲ្យធ្វើយុវជនកងចល័ត?

ថែវ ៈ ស៊ីកហើយគេឲ្យមកផ្ទះវិញ បាទ!ឲ្យមកធ្វើកងចល័ត មេភូមិ ។

ធានី ៈ មកដល់ភូមមអ្នកណាគេអ្នកចាត់តាំងឲ្យពូទៅធ្វើ?

ថែវ ៈ មេ គេហៅបើយើងគេហៅ មេសង្កាត់ គណៈសង្កាត់ ។

ធានី ៈ គណៈសង្កាត់គេឈ្មោះអីគេ?

ថែវ ៈ ឈ្មោះ សាំ ស្អីសាំទេ ដាក់តែសាមបានហើយ ។

ធានី ៈ សាំៗនឹងគណៈសង្កាត់អីគេ?

ថែវ ៈ គណៈសង្កាត់ថ្មពួកយើង គេហៅគណៈសង្កាត់ថ្មពួក ។

ធានី ៈ ជាអ្នកចាត់តាំងឲ្យពូ?

ថែវ ៈ ចាត់តាំងឲ្យខ្ញុំធ្វើជា ហៅថាប្រធានយុវជន ។

ធានី ៈ ប្រធានយុវជននឹងគ្នាប៉ុន្មាននាក់?

ថែវ ៈ ដូចក្តាប់ម៉ាយុវជនកាលនឹងច្រើនដែរ ម៉ាភូមិនឹងក្តាប់ទាំងអស់ ។

ធានី ៈ ក្តាប់ម៉ាភូមិនឹងប៉ុន្មាននាក់ទៅ?

ថែវ ៈ បើគិតទៅជាង១០០នាក់ ។

ធានី ៈ ជាង១០០នាក់?

ថែវ ៈ បាទ!

ធានី ៈ យុវជន តែយុវជនទេ យុវនារីផ្សេងទៀត?

ថែវ ៈ យុវនារី មានប្រធាននារីផ្សេងទៀត មានប្រធាននារីគេ ។

ធានី ៈ ជាង១០០នាក់ ។ ហើយពូថាការងាររបស់ពូនៅនឹងគឺធ្វើការអីគេ បិទភ្លឺស្រែ?

ថែវ ៈ បិទភ្លឺស្រែៗទាំងយប់ទាំងថ្ងៃ ធ្វើស្ទូងដក ។

ធានី ៈ ចុះខែប្រាំងធ្វើអីគេវិញ?

ថែវ ៈ ខែប្រាំងបិទភ្លឺ ។

ធានី ៈ បិទភ្លឺដែរ?

ថែវ ៈ បាទ! ខែប្រាំងបិទភ្លឺ ។

ធានី ៈ ចុះពូថានៅឆ្នាំ៧៦បិទត្រពាំងថ្មម៉េច បិទអាង?

ថែវ ៈ ក្រោយពីក្នុងចន្លោះនោះ គឺដល់ឆ្នាំ៧៦ ឲ្យកម្លាំងយុវជន យុវនារីទៅបិទអាងត្រពាំងថ្ម ។

ធានី ៈ បិទអាងត្រពាំងថ្ម បិទយ៉ាងម៉េចពូ?

ថែវ ៈ បិទអាងៗយើងសព្វថ្ងៃនេះ ធ្វើអាងៗ ។

ធានី ៖ យើងលើកដីក?

ថែវ ៖ លើកដីកធ្វើអាង ។

ធានី ៖ ដូចទំនប់?

ថែវ ៖ ក្នុងម៉ាតំបន់៩គឺទៅទាំងអស់ មនុស្សរាប់សែននាក់ ។

ធានី ៖ តែពូក្តាប់១០០នាក់ដដែល?

ថែវ ៖ បាទ! ក្តាប់១០០នាក់ ។

ធានី ៖ ហើយពូនៅនឹង ពូមិញថាកូនក្រុមពូឈ្មោះអីគេខ្លះ ពូក្តាប់១០០នាក់ចឹងវាមានប្រធាន?

ថែវ ៖ មានប្រធានក្រុម មានកូនក្រុមមានអី ។

ធានី ៖ អនុប្រធានពូឈ្មោះអីគេ?

ថែវ ៖ អនុប្រធានឡាក់ កប ងាប់ហើយ ងាប់ប៉ុន្មានថ្ងៃមុននេះឯង ។

ធានី ៖ ឡាក់ កប?

ថែវ ៖ បាទ!

ធានី ៖ អ្នកណាគេទៀតពូ?

ថែវ ៖ វ៉ាន់ ពឹក សមាជិករង ។

ធានី ៖ សមាជិក?

ថែវ ៖ បាទ!

ធានី ៖ វ៉ាន់ តឹក?

ថែវ ៖ វ៉ានៗ ។

ធានី ៖ វ៉ាន តឹក?

ថែវ ៖ បាទ!

ធានី ៖ គាត់នៅរស់ទេ?

ថែវ ៖ នេះនៅរស់ ។

ធានី ៖ រស់នៅណាវិញ?

ថែវ ៖ នេះនៅភូមិនេះ?

ធានី ៖ តែប៉ុននឹងទេ?

ថែវ ៖ បាទ!

ធានី ៖ ហើយពូធ្វើជាប្រធានយុវជនចឹង ហើយពូគ្រប់គ្រងនៅនឹង ពូធ្វើការងារនឹង ទទួលបញ្ជាពីអ្នកណាគេមកវិញ?

ថៃវ ៖ ទទួលបញ្ជាពីប្រធានសហករណ៍។

ធានី ៖ ប្រធានសហករណ៍ឈ្មោះអីគេ?

ថៃវ ៖ ឈ្មោះ សាំនីងឯង។

ធានី ៖ សាំនីងជាអ្នកបញ្ជាពូឲ្យទៅ?

ថៃវ ៖ បាទ! មានគេ មេភូមិយើងទៀត មេភូមិនឹងមើលពីយើងទៀត។

ធានី ៖ មេភូមិនឹងឈ្មោះអីគេ?

ថៃវ ៖ ឈ្មោះស្ដីឡែប លែន ឡែប។

ធានី ៖ លែន ឡែប?

ថៃវ ៖ នោះ សព្វថ្ងៃទៅអាមេរិចហើយ។

ធានី ៖ អូ! ទៅអាមេរិចទៀត?

ថៃវ ៖ បាទ! ដែលហ៊ាននៅៗគេវ៉ៃចោល។

ធានី ៖ ឈ្មោះ លែន ឡែប?

ថៃវ ៖ បាទ! លែន ឡែប។

ធានី ៖ ចឹងគាត់មេភូមិនឹង គាត់អ្នកបញ្ជាពូថែមទៀត?

ថៃវ ៖ បាទ! ត្រូវមើលយើង គាត់អ្នកជ្រើសតាំងយើង តែងតាំងយើង បញ្ជាឲ្យយើងធ្វើការងារអីគេនេះឯង នេះពួកនារីៗ នេះសម័យនោះនារីៗប្រធាននារី។

ធានី ៖ គាត់ប្រធាននារី?

ថៃវ ៖ ទេ! កូនក្រុមគេ ពួកកូនក្រុមគេ។

ធានី ៖ ចឹងប្រធាននារីស្រីឈ្មោះអីពូ?

ថៃវ ៖ ហ៊ុន។

ធានី ៖ គាត់នៅរស់ទេ?

ថៃវ ៖ នៅរស់។

ធានី ៖ នៅណាវិញ?

ថៃវ ៖ នៅព្រៃត្បូងនោះ នៅធ្វើស្រែ។

ធានី ៖ ឈ្មោះអីគេហ៊ុន?

ថៃវ ៖ ម៉ែន ហ៊ុន ដាក់តាៗ ត្រកូលតាទៅ ។

ធានី ៖ ម៉ែន ហ៊ុនហ្នឹងប្រធាននារីយុវជន?

ថៃវ ៖ នារីៗភូមិ ប្រធាននារីភូមិ ។

ធានី ៖ ក្តាប់១០០នាក់ដែរ ដូចពូដែរ?

ថៃវ ៖ បាទៗ ។

ធានី ៖ នៅភូមិស្វាយយើងដែរ?

ថៃវ ៖ បាទ!

ធានី ៖ ចឹងពូ ពេលយើងធ្វើការនៅត្រពាំងថ្ម ទាំងនារី និងបុរសធ្វើដូចគ្នា ឬក៏ផ្សេងគ្នា?

ថៃវ ៖ ធ្វើដូចគ្នា ទាំងយប់ទាំងថ្ងៃដូចគ្នា ធ្វើការជុំគ្នា បើសិនជាយុវជនកាប់ដី នារីរែក នេះពួកនេះឯង ពួកក្រុមនេះឯង ។

ធានី ៖ ចឹងពូថា ពូធ្វើនៅត្រពាំងថ្មនឹង អាងវាប៉ុន្មាន ប្រហែលន្មាន ហើយគេ?

ថៃវ ៖ អូ! អាងនឹងធំណាស់ អាងនឹងបើគិតទៅ មើលអាងត្រពាំងថ្មយើងលើពីលិចស្ពានទី៣មកទៅ ដល់កែងកាច យើងទៅលើកអាគេហៅកូនខ្វែងទៀតនោះ អាគេខាងលិចកូនខ្វែងទំនប់អាង បិទម៉ារួច បានឲ្យយើងជីកព្រែកចេញពីស្ពានទី១មក ទៅខាងទៅព្រៃមាន់ពីទៅដល់ថ្នល់ទៅ ព្រៃមាន់ ។

ធានី ៖ ចឹងពូដឹងថាអាងមានប្រវែងប៉ុន្មានទេ ទទឹងប៉ុន្មាន បណ្តោយប៉ុន្មាន?

ថៃវ ៖ អូ! មិនដឹងស្មានត្រូវទេ ។

ធានី ៖ ជម្រៅវា អត់ដឹង?

ថៃវ ៖ អត់ទេ បើដឹងថាដល់មិនបានពិចារណាបើធំៗអាងនោះ អាងធំ បើយើងម៉ាខេត្តយើង ត្រង់នេះមានតែអាងត្រពាំងថ្មនេះឯងវត់លេខមួយធំជាងគេ ។

ធានី ៖ ហើយកាលពូទៅសមាជិកពូមានបាត់បង់អីទេ ពេលទៅលើកអាងត្រពាំងថ្មទេ?

ថៃវ ៖ ពួកយើងអត់មានងាប់មួយទេណា អត់មានអ្នកណាងាប់មួយទេ ។

ធានី ៖ អត់ទេ?

ថៃវ ៖ អត់ទេ ។

ធានី ៖ ចឹងការហូបចុកអីម៉េចដែរ នៅអាងនឹង?

ថៃវ ៖ ហូបចុក កាលនឹងហូបចុកគ្រប់គ្រាន់ទៅណា អាងគេឲ្យអី!ដាក់ទឹកដីក ចែកទឹកដីក បើរុយៗវិញខ្មោងងឹតរុយ ។

ធានី : ម៉េចចឹងពូ?

ចែវ : រុយដូចថាវាធំក្លិនវាទៅស៊ីអាបាយផ្អូម មកនៅចាក់ចោលពេញណាពេញណែ បាយក្រហម បាយអី ។ ហើយទឹកចែកគ្នាផឹក ចែកគ្នាផ្លូតវេទនាណាស់ ដើរជុំគ្នាមិនបានទេ ធុំដើរគ្នា ។

ធានី : ម៉េចចឹងពូ ម៉េចខ្វះទឹកវិញ?

ចែវ : ចុះមានទឹកណាផឹក បើផឹកទឹកដីងមកពីណា ដឹកតាមរទេះគោទៅយកណា បើកន្លងមកមិនមានទឹកបិទអាង ។ អាងនឹងពីដើមមិញ មិនមែនជាទួលអាងទេ ជាថ្នល់បុរាណៗយើងបិទធ្វើជាងអាង បិទយកថ្នល់បូរាណធ្វើអាង ពីដើមមិញមានមានអាងណាថ្នល់បូរាណ ។

ធានី : ថ្នល់បូរាណនឹងវាយូរហើយ?

ចែវ : បាទ! ថ្នល់បូរាណចេញពីទន្លេ ។

ធានី : ថ្នល់នឹងវាម៉េច វាទូលាយ?

ចែវ : ថ្នល់មើល ថ្នល់ចេញពីទន្លេទៅបុកទៅភ្នំស្រុក ដល់យើងបិទលើថ្នល់ទន្លេនឹង ដល់មកជិតដល់ភូមិស្អី ភូមិប៉ោយចារអាភូមិភ្នំកើត បាទ!អឺ!ដល់ភូមិពង្រ យើងបិទជិតដល់ភូមិពង្រ គេបិទកាត់ខាងកើតខាងនេះភូមិពង្រ បិទធ្វើជាទំនប់ខាងនេះ ទប់ថ្មី អត់មានអានេះទំនប់សុទ្ធសាធ អត់មានអាងទេ អត់មានភ្លឺទេ បិទកាត់វាលស្រែទៅ បិទធំ បិទសុទ្ធតែដី រត់ ។

ធានី : ចឹងគេពូនដីឡើងលើវិញ?

ចែវ : ពូនដីឡើងលើ ដឹកដី នាំគ្នាលើកឡើង ។

ធានី : ចឹងថ្នល់បូរាណនឹង មិនជីកគាស់ដែរ?

ចែវ : អត់ទេ ជីកលប់ ។

ធានី : ជីកលប់វិញ?

ចែវ : បាទ!អានេះ ចាំមើលអានេះថ្នល់ពីទន្លេមកៗឆ្ងាយមកចេះមក អានេះភូមិចារ ភូមិប៉ោយចារ ភូមិប៉ោយស្នួល នោះប៉ោយពង្រ អានេះថ្នល់អាងមួយទៀតជិតទៅទៀតចេះហើយទៀតនេះភូមិគេហើយ ភូមិមកនេះ ។

ធានី : ចឹងបន្ទាប់មកទៀត អានេះគេគូសចេះមកទៀតទៅ?

ចែវ : បាទ!

ធានី : ហើយជុំវិញនឹងថ្នល់ ចុះអាកណ្តាលនឹងស្អីគេទៅ?

ចែវ : នេះទួលអាង ។

ធានី : ទួលអាងនឹងក្នុងទួលអាងនឹងវាលស្រែ ឬក៏មាន?

ថែវ ៖   វាលស្រែៗ ។

ធានី ៖   មិនមែនមានប្រាសាទមានអី?

ថែវ ៖   អត់មានប្រាសាទទេ វាលស្រែ ។

ធានី ៖   វាលស្រែសុទ្ធ?

ថែវ ៖   បាទ! វាលស្រែសុទ្ធ ។

ធានី ៖   ហើយកន្លែងនឹងម៉េចបានគេយកកន្លែងនឹង?

ថែវ ៖   អានេះស្ពានបូរាណមួយទៀត ស្ពានបូរាណ ស្ពានសម័យអង្គរ ស្ពានធ្វើពីថ្មបាយក្រៀម គេហៅស្ពានរាបៗ ពួកខ្ញុំបិទលុបអានេះ បិទស្ពាននេះ ។

ធានី ៖   ចឹងបិទស្ពាននឹងបាត់ហើយ?

ថែវ ៖   បិទលុបចោល បិទលុបអាស្ពាននេះចោលៗ បិទលុបអាតួទៅឆ្លងអាង ។

ធានី ៖   ចឹងធម្មតាពូដែលមានស្ពាន ប្រាកដមានអូរគេ?

ថែវ ៖   បាទ! នោះមុខដាច់ៗគេ ស្ពាននោះដាច់បាត់ហើយ ។

ធានី ៖   ប៉ុន្តែយើងបិទលើអាស្ពានបូរាណ?

ថែវ ៖   បិទលុបចោល ។

ធានី ៖   ចឹងអាអូរនឹងមានដែរៗ វាមានអូរដែរ ឬក៏អត់ទេ?

ថែវ ៖   អូរនេះដោយសារមុខស្ពានគេទេ ពីដើមមិញ ។

ធានី ៖   ប៉ុន្តែអត់មានទឹកទេ?

ថែវ ៖   អត់មានទឹកទេ អត់មានទឹក ។

ធានី ៖   ហើយចឹងជីកជម្រៅប្រហែលប៉ុន្មាន?

ថែវ ៖   ជីកជម្រៅម៉ាម៉ែត្រ ជម្រៅជាងម៉ាម៉ែត្រទៅឆ្ងាយថ្នល់ប្រហែលពីនេះទៅថ្នល់ជាតិនោះ បើខ្ញុំវែកៗប្រហែលនេះចំងាយ១០០ម៉ែត្រជាង ។

ធានី ៖   វែកចុះៗ ជម្រៅចុះ?

ថែវ ៖   ទេ! វែកឆ្ងាយពីនេះ ទៅចាក់ដីលើខ្នងអាងដូចឡើងភ្នំចឹងៗមើលទៅមនុស្សសន្ធឹម ។

ធានី ៖   ចឹងជីកពីក្រោមម្ដងតិចៗឡើងលើ?

ថែវ ៖   បាទៗ កំពស់ដូចភ្នំ ។

ធានី ៖   ប្រហែលជាប៉ុន្មានម៉ែត្រ ពូស្មានមើលទំនប់?

ថែវ ៖   ទំនប់ ។

ធានី ៖ ៥-៦ម៉ែត្រ ៧-៨ម៉ែត្រ?

ថៃវ ៖ ខ្ពស់វា ។

ធានី ៖ អត់ទេ ពីក្រោមឡើងលើ ជម្រៅវាពីក្រោមឡើងលើដែលពូថាជីកឡើងដូចពូប្រាប់ថាជីកឡើងដូចឡើង?

ថៃវ ៖ ជីកឡើងបើគិតទៅវាប្រហែលជា៦ម៉ែត្រចេះឯង វាទំរេឡើងចឹង ។

ធានី ៖ ៦ម៉ែត្រពីក្រោមឡើងលើ?

ថៃវ ៖ បាទ! ជាធម្មតា ។

ធានី ៖ ដល់ពេលអាខ្ពស់វាអត់ដឹងប៉ុន្មាន?

ថៃវ ៖ ខ្ពស់វាប្រហែល៥ម៉ែត្រទៅ៦ម៉ែត្រ ឬ៧ម៉ែត្រ ។

ធានី ៖ ទទឹង?

ថៃវ ៖ ទទឹងវា បាទ!ទទឹងវា ធំណាស់ ។

ធានី ៖ អានឹងខ្ពស់អាង?

ថៃវ ៖ បាទ! ខ្ពស់អាង អានេះទៅខ្ពស់វាចេះ ទូលខ្ពស់ទទឹងចេះ ។

ធានី ៖ បណ្ដោយប៉ុន្មាន?

ថៃវ ៖ បណ្ដោយ បើគិតពីខាងកើតទន្លេទៅប្រហែលជា៧គីឡូ ។

ធានី ៖ ៧គីឡូ?

ថៃវ ៖ មកនេះប្រហែលជា៧គីឡូ ។

ធានី ៖ ៧គីឡូ បួនជ្រុង?

ថៃវ ៖ បាទ! ៧គីឡូ៤ជ្រុង ធំណាស់អាងនឹងធំណាស់ ពុតាមប៉ុស្តិ៍ផ្សាយដែរតើ អាង ។

ធានី ៖ ចឹងពូដឹងថាអ្នកណាគេអ្នកដឹកនាំធ្វើអាង?

ថៃវ ៖ គណៈតំបន់ ។

ធានី ៖ គណៈតំបន់ហ្នឹង?

ថៃវ ៖ គណៈតំបន់ គណៈភូមិភាគ ។

ធានី ៖ ឈ្មោះអៀម ឡៃហ្នឹង ។ អៀម ឡៃ គណៈតំបន់រឺង ឬក៏ប្រធានធំ?

ថៃវ ៖ ចាំមើលណា គណៈប្រធានគេឈ្មោះ ហ៊ីង។ បាទ!លោក ហ៊ីង ។

ធានី ៖ ពូដឹងស្អីគេហ៊ីងទេ?

ថៃវ ៖ មិនដឹងត្រកូល ហ៊ីងទេ មិនដឹងទេ ស្អីហ៊ីងទេ ។

ធានី ៖ គ្រាន់ដឹងថាហ៊ីង?

ថែវ ៖ បាទ!

ធានី ៖ គណៈតំបន់ហ៊ីង?

ថែវ ៖ ហ្នឹងហើយ អៀង ឡែវង អានោះ ។

ធានី ៖ ហ៊ីងហ្នឹង អ្នកនិរតី ឬក៏អ្នកបូព៌ាយើង អឺ!ពាយ័ព្យ?

ថែវ ៖ អ្នកពាយ័ព្យ បាទ! ។

ធានី ៖ អ្នកពាយ័ព្យ?

ថែវ ៖ បាទ!

ធានី ៖ ចុះដឹងថាបន្ទាប់ពីហ៊ីងនឹងទៅ មានអ្នកណាគេ?

ថែវ ៖ រួចអៀង ឡៃចឹងដែរ ។

ធានី ៖ អៀង ឡៃ ចាំ!?

ថែវ ៖ ហើយគណៈស្រុក ឆាត ។

ធានី ៖ គណៈស្រុកឆាត?

ថែវ ៖ ហ្នឹង ឆាត នោះក្តាប់ម៉ាស្រុកយើង នៅក្តាប់ស្រុកខ្ញុំ ។

ធានី ៖ ឆាតៗនឹងជាអីគេ?

ថែវ ៖ ជាគណៈស្រុកថ្មពួកយើងនេះ ។

ធានី ៖ គណៈស្រុកថ្មពួក ។ ចុះអ្នកណាគេទៀតអនុគាត់?

ថែវ ៖ អនុគាត់ទៀតឈ្មោះ ហួតៗ ។

ធានី ៖ ពួកហ្នឹងខាងបូព៌ា អឺ!ពាយ័ព្យដែរ?

ថែវ ៖ ពាយ័ព្យទាំងអស់ ម៉ាសេរីពាយ័ព្យទាំងអស់ ដែលធ្វើអាងពួកពាយ័ព្យទាំងអស់ អត់ទាន់មានគេ ទេ ។

ធានី ៖ ចឹងអាងហ្នឹងធ្វើតាំងឆ្នាំប៉ុន្មាន ពីដំបូងមក?

ថែវ ៖ អឺ!

ធានី ៖ កសាងដំបូង?

ថែវ ៖ ឆ្នាំ៧៧/៦ ។

ធានី ៖ ៧៦បានចាប់ផ្តើមកសាង?

ថែវ ៖ បាទ! បានចាប់ផ្តើម ។

ធានី ៖ ចឹងពេលពូចូលទៅបានចាប់ផ្ដើមធ្វើ?

ថែវ ៖ ចាប់ផ្ដើមថ្មីចេះ អត់ទាន់មានអ្នកណាធ្វើទេ ។

ធានី ៖ ចឹងបានន័យថាដំបូងគឺវាវាបស្មើ?

ថែវ ៖ អឺ! ស្មើ មានតែផ្ទាល់ឌុប មានតែផ្លូវនោះផ្លូវព្រៃ ផ្ទាល់បូរាណសុទ្ធតែព្រៃ មានតែអាគ្រាក់មួយ សម្រាប់ឈូសដើមឈើចោល ឈូសដើមឈើដុះលើផ្ទាល់យើងក៏វែកដីដាក់ ។

ធានី ៖ វែកដីដាក់?

ថែវ ៖ អឺ! វែកដីដាក់ ។

ធានី ៖ ពូដឹងថាហេតុអីបានគេកសាងទំនប់ហ្នឹងទេ?

ថែវ ៖ គេកសាងសម្រាប់ទុកធ្វើស្រែ ។

ធានី ៖ គេប្រាប់ចឹង?

ថែវ ៖ បាទ! ធ្វើស្រែ ។

ធានី ៖ ចុះបន្ទាប់មកពី ពូដឹងថាហ៊ុនហ្នឹងត្រូវគេចាប់ទៅអត់ទេ?

ថែវ ៖ ដឹង ។

ធានី ៖ ឆ្នាំប៉ុន្មាន?

ថែវ ៖ ហ៊ុននោះចាប់ក្នុងចន្លោះឆ្នាំចុង៧៦ ។

ធានី ៖ ចុង៧៦?

ថែវ ៖ បាទ! ជិតចូលជិត៧៧ ។

ធានី ៖ ចឹងពូធ្វើការបានប្រហែលជិតម៉ាឆ្នាំ?

ថែវ ៖ បាទ! នៅ២ឆ្នាំ ខ្ញុំ ។

ធានី ៖ ពូចូលកងចល័ត៧៦?

ថែវ ៖ ៧៦ ៧៧ៗ នៅបិទអាង២ឆ្នាំ ។

ធានី ៖ ចឹងចុង៧៧?

ថែវ ៖ ចុងៗ ជិតខ្ញុំរត់ ។

ធានី ៖ ចឹងចុង៧៦ ឬចុង៧៧?

ថែវ ៖ ដឹង!

ធានី ៖ ដែលហ៊ុនត្រូវគេចាប់?

ថៃវ ៖ ចុង៧៦ បាទ! ជិតចូល៧៧ បើឆាតចាប់៧៧ ដើម៧៧ ឆាត ។

ធានី ៖ ហ៊ឹងហ្នឹងថីបានគេចាប់ ពូដឹងទេ?

ថៃវ ៖ គេចោទថថា បើកាលនោះគេចោទថាយើងក្បត់ គេថាយើងក្បត់គេថាហ៊ឹង ឆាត អៀង ឡៃ នេះ គឺជាភូមិភាគពាយ័ព្យនេះ គឺមានគំនិតក្បត់ ប្រុងនាំចល័តផ្ទើទ័ពដើម្បីវើបម្រាស់វើបកទៅ គេវិញ ។ ថាយើងរៀបទ័ព ប្រុងរៀបកម្លាំងរៀបអីណាទេ ។

ធានី ៖ ចឹងចោទថា៣នាក់នឹងរៀបកម្លាំង?

ថៃវ ៖ បាទ! រៀបកម្លាំង រៀបការសម្លាប់ ។

ធានី ៖ រៀបកម្លាំង អឺ!កងចល័ត?

ថៃវ ៖ កងចល័តវើបក ។

ធានី ៖ វើបកអីគេ?

ថៃវ ៖ វើបកពូៗខាងប៉ុលពត ថាយើងអ្នកជាតិនិយមវើបំរាស់វិញ ។

ធានី ៖ អ្នកជានិយមចឹង?

ថៃវ ៖ បាទ!

ធានី ៖ ហើយកាលនឹងមានការចាប់មេធំហើយ?

ថៃវ ៖ កាលដែលចាប់ឆាតចាប់នៅកន្លែងការដ្ឋានខ្ញុំ ចាប់ហ៊ឹងគេចាប់នៅគល់រំចេក ហៅការដ្ឋានរួមគេនឹង គល់រំចេកគឺកន្លែងការដ្ឋានតំបន់ ។

ធានី ៖ ការដ្ឋានតំបន់៥ហ្នឹង?

ថៃវ ៖ បាទ! តំបន់៥ ។

ធានី ៖ គល់រំចេកនៅណាវិញ?

ថៃវ ៖ គល់រំចេកនៅៗត្បូងភ្នំស្រុក អាផ្លូវទៅចេញពីទ័ពបោះមក នៅខ្វែងអាផ្លូវខ្វែង ចេញពីព្រៃមាន់មកវាខ្វែង ហៅគល់រំចេកការដ្ឋានធំ ។

ធានី ៖ កន្លែងទីស្នាក់ការ?

ថៃវ ៖ ស្នាក់ការកណ្ដាល ។

ធានី ៖ ស្នាក់ការកណ្ដាល តំបន់៥ចឹងពូ?

ថៃវ ៖ តំបន់៥ បាទ!

ធានី ៖ ម៉េចទៀតពូ គេទៅចាប់ ចាំមើលហ៊ឹងគេចាប់នៅទីស្នាក់ការហ្នឹង ដល់ឆាតគេចាប់នៅកន្លែងការដ្ឋាន?

ថែវ ៖ ឆាត គេមកចាប់នៅកន្លែងការដ្ឋាន។

ធានី ៖ ចុះអៀង ឡៃ?

ថែវ ៖ អៀង ឡៃ មិនដឹងចាប់ត្រង់ណាទេ អៀង ឡៃ គាត់ជាអ្នកមុខការឲ្យខ្ញុំ អៀង ឡៃនឹងដើម្បី ធ្វើគណៈអធិបតីការឲ្យខ្ញុំ អៀង ឡៃ។ ប៉ុន្តែ ដល់ពេលបាត់គាត់មិនដឹងជាបាត់ចាប់ដែល សង្ស័យចាប់ៗនៅកន្លែងខេត្ត។

ធានី ៖ នៅឆ្នាំប៉ុន្មានដែរ?

ថែវ ៖ ក្នុងឆ្នាំ៧៥ហ្នឹងឯង អូ!ដើម៧៧ហ្នឹងឯង ចាប់ៗខែនឹងបាំងខែហ្នឹងពួកនេះ អត់មានចាប់ឆ្ងាយគ្នាទេ។

ធានី ៖ ចឹង?

ថែវ ៖ ចាប់រស់ ញ៉ឹមមុន រស់ ញ៉ឹមចាប់មុន គណៈភូមិភាគ។

ធានី ៖ ចុះបន្ទាប់ពីហ៊ឹងហ្នឹងទៅអ្នកណាគេជំនួស?

ថែវ ៖ គេឈ្មោះ តាយ៉ុយ។

ធានី ៖ តាយ៉ុយ?

ថែវ ៖ តាយ៉ុយ ចាប់ពួកហ្នឹងបានឡើងពាក់តាយ៉ុយ។

ធានី ៖ តាយ៉ុយ ជាប្រធានតំបន់៥?

ថែវ ៖ អត់តែងតាំងជាប្រធានផង គេហៅថាប្រធានបណ្តោះអាសន្នហៅថាប្រធានប្រចាំការណ៍ការដ្ឋាន។

ធានី ៖ ការដ្ឋានត្រពាំងថ្មហ្នឹង?

ថែវ ៖ បាទ! ការដ្ឋានហ្នឹងឯង។

ធានី ៖ បន្ទាប់មកទៀត អ្នកណាគេទៀត ក្រៅពីតាយ៉ុយ?

ថែវ ៖ តាយ៉ុយមកខ្ញុំ នៅចន្លោះដែលខ្ញុំបួសស្រូវគេចាប់យកទៅធ្វើ បាត់ខ្ញុំចន្លោះឯង។

ធានី ៖ ចឹងពេលតាយ៉ុយមកឆ្នាំប៉ុន្មាន?

ថែវ ៖ ឆ្នាំ៧៧នោះឯង។

ធានី ៖ ១៩៧៧តាយ៉ុយមក?

ថែវ ៖ បាទ!

ធានី ៖ ចឹងសុំបកក្រោយ កន្លែងពូថាពូធ្វើ?

ថៃវ ៖ តាយ៉ុយមកនេះ គេបញ្ជូលអ្នកនិរតីមកហើយ នីរតិចូលផងហើយ ។

ធានី ៖ ចឹងតាយ៉ុយអ្នកនិរតី?

ថៃវ ៖ តាយ៉ុយៗអ្នកពាយ័ព្យ ប៉ុន្តែពេលតែងតាំងតាយ៉ុយនេះនិរតីមកដងហើយ មកអែបគាត់នោះហើយ ។

ធានី ៖ ស្គាល់ឈ្មោះគាត់ទេ?

ថៃវ ៖ ឈ្មោះ សៀម អូ!នែក!ឈ្មោះ សឿន ។

ធានី ៖ សឿន?

ថៃវ ៖ សឿន

ធានី ៖ សឿនហ្នឹង មកកាន់ការមកជាមួយតាយ៉ុយផងដែរ?

ថៃវ ៖ មកពីគាត់នេះ ស្រុកគេឈ្មោះ ស្រុកនៅតាកែវ សឿន ។

ធានី ៖ ខេត្តតាកែវ?

ថៃវ ៖ ខេត្តតាកែវ បាទ!

ធានី ៖ អត់ដឹងស្រុកអីទេ?

ថៃវ ៖ នៅខេត្តតាកែវ ថាមកពីតាកែវៗ ។

ធានី ៖ ចឹងតាយ៉ុយហ្នឹងអ្នកកាន់ ប្រធានការដ្ឋានហ្នឹងបណ្ដោះអាសន្នទេ?

ថៃវ ៖ បណ្ដោះអាសន្នទេ គាត់តែងតាំងយើងកុំឲ្យបាក់ទឹកចិត្ត អាចល័តចាស់យើងកុំឲ្យបាក់ទឹកចិត្ត ពេលនោះក៏គេតែងតាំងមិនបានដល់ម៉ាខែ គេចាប់យកទៀត ។

ធានី ៖ រយៈពេលម៉ាខែក្រោយ?

ថៃវ ៖ បាទ! ម៉ាខែក្រោយគេចាប់តាយ៉ុយទៀត ។

ធានី ៖ ម៉ាខែក្រោយគេចាប់តាយ៉ុយទៀត?

ថៃវ ៖ បាទ!

ធានី ៖ ហើយបន្ទាប់មកអ្នកណាគេឡើងជំនួស?

ថៃវ ៖ សឿននោះឯង និរតី សុទ្ធតែបញ្ជូននិរតីមកទាំងអស់ ។

ធានី ៖ ចឹងកាលដំបូង តាយ៉ុយបណ្ដោះអាសន្នបានម៉ាខែ បានសឿនហ្នឹងឡើងកាន់?

ថៃវ ៖ បានឡើងកាន់ ។

ធានី ៖ ប៉ុន្តែពេលនឹង សឿនមកហើយ?

ថែវ ៖ សឿនមកហើយៗ នៅជុំជាមួយគ្នា ប៉ុន្តែគេមិនទាន់ទៅចាប់ខ្លួន គេមកស៊ើប ។

ធានី ៖ ដល់ពេលក្រោយមកទៀត បានសឿនឡើងជំនួស?

ថែវ ៖ ឡើងជំនួស បាទ ។

ធានី ៖ ដល់ពេលក្រោយមកពូដឹងរឿងហ្នឹងក៏រត់មក?

ថែវ ៖ ខ្ញុំរត់បាទ!

ធានី ៖ រត់មកភូមិ?

ថែវ ៖ ពីព្រោះដឹងថាគេនឹងចាប់បន្តៗទៀត ចាប់ក្រោមទៀត ដល់ពេលគេចាប់គាយ៉ុយរួចហើយ វាចាប់មកខាងគណៈគ្រប់គ្រងស្រុក គណៈគ្រប់គ្រងភូមិ ។ គណៈគ្រប់គ្រងភូមិខ្ញុំ ដែលក្តោបពីលើខ្ញុំទៀតឈ្មោះ នែក! ឈ្មោះអីអាភូមិថ្មីហ្នឹង ដែលភូមិថ្មី អាធៀវ អាពាវ ភ្លេចឈ្មោះវាភ្លេចយូរហើយពេក ។

ធានី ៖ ចឹងសាំហ្នឹង?

ថែវ ៖ សៀវៗឈ្មោះសៀវ ។

ធានី ៖ ចឹងសៀវហ្នឹងជំនួសសាំ?

ថែវ ៖ សៀវនេះជំនួសសាំ សាំៗគេនៅថ្មពួកនេះ គេឲ្យសៀវនោះជំនួសក្តាប់ចល័តនោះ ។

ធានី ៖ ចល័តភូមិថ្មពួកហ្នឹង?

ថែវ ៖ តាមភូមិថ្មពួក គេឲ្យក្តាប់ចល័តភូមិថ្មពួក នេះចាប់សៀវមកទៀតឲ្យតែខាងភូមិភាគពាយ័ព្យគេចាប់ទាំងអស់ ឲ្យតែថ្នាក់ក្រោមៗចាប់បណ្តើរៗ ។

ធានី ៖ ឈ្មោះ សៀវ?

ថែវ ៖ បាទ!

ធានី ៖ ឈ្មោះ សៀវ មកជំនួសសាំ?

ថែវ ៖ សាំ បាទ!

ធានី ៖ ដល់ពេលសាំទៅណាទៀត?

ថែវ ៖ សាំនៅថ្មពួកហ្នឹងឯង ។

ធានី ៖ ប៉ុន្តែសៀវ មកជំនួសសាំ ចឹងសាំគាត់ទៅណា?

ថែវ ៖ សាំនៅនេហ ប៉ុន្តែសាំក៏គេចាប់យកទៅដូចគ្នា ។

ធានី ៖ សាំយកទៅណា ដឹងគេចាប់?

ថែវ ៖ មិនដឹងស្លាប់ សាំនៅនេះ ប៉ុន្តែសាំក៏គេចាប់ដូចគ្នាមកនេះ ។

ធានី ៖ សាំយកទៅណាដឹងគេចាប់យកទៅណា?

ថៃវ ៖ នេះស្លាប់ គេចាប់នេះបង ចាប់សាំនេះ ចាប់សាំរួចបានគេឡើងភី តែងតាំងភី ឈ្មោះអាភី ។

ធានី ៖ ចុះសៀវនោះ?

ថៃវ ៖ អាសៀវនោះគេចាប់ផ្សេង នៅចល័ត នៅក្តោប ជាអ្នកក្តោបចល័ត សៀវនេះខាងអ្នកក្តាប់ចល័ត ឯសាំនេះអ្នកក្តាប់ការដ្ឋានក្នុងឃុំមួយនេះឯង ។

ធានី ៖ ព្រោះសាំហ្នឹងមិនមេឃុំដំបូង?

ថៃវ ៖ សាំ មេឃុំ ។

ធានី ៖ ហើយពូថាគ្រប់គ្រងពូដែរ?

ថៃវ ៖ បាទ! គ្រប់គ្រងខ្ញុំដែរ ។

ធានី ៖ ដល់ពេលសៀវហ្នឹង?

ថៃវ ៖ សៀវហ្នឹងគេតែងតាំងឲ្យយើង ឲ្យសៀវហ្នឹងធ្វើអ្នកក្តាប់ចល័តវិញ ។

ធានី ៖ ហើយឈប់ឲ្យសាំគ្រប់គ្រងពូហើយ?

ថៃវ ៖ សាំនៅៗក្តាប់ភូមិនេះ ។

ធានី ៖ ដល់ពេលហើយគេចាប់សៀវអត់?

ថៃវ ៖ ចាប់សៀវៗ ។

ធានី ៖ ចាប់សៀវទៀត?

ថៃវ ៖ បាទ! ចាប់សៀវទៀត ។

ធានី ៖ ចាប់កងចល័ត?

ថៃវ ៖ បាទ!

ធានី ៖ ចាប់កងចល័តទាំងស្រីទាំងប្រុស?

ថៃវ ៖ ទាំងស្រីទាំងប្រុស បាទ!ចល័តរួមម៉ាឃុំ ។

ធានី ៖ សៀវ ក្តាប់កងចល័ត ហើយត្រូវគេចាប់ខ្លួន?

ថៃវ ៖ ចាប់ខ្លួន ។

ធានី ៖ សាំ គេចាប់សាំហើយជំនួសអ្នកណាគេ?

ថៃវ ៖ សាំ ដល់ចាំមើលចាប់សាំហើយជំនួសភីៗ ឡើងភីទៀត ។

ធានី ៖ ភីមកពីនិរតី?

ថៃវ ៖ ភីហ្នឹង ពាយ័ព្យទៀត ។

ធានី ៖ ភី ពាយ័ព្យដែរ?

ថែវ ៖ បាទ! តែភីគេចាប់ តែងតាំងបញ្ឈរដូចគ្នា ដល់ភីឡើងមិនបានម៉ាខែ ឡើងមកបានគេឡើងអ៊ឹមៗនេះ និរតីហើយចូលមក អ៊ឹមនេះនិរតី ឡើងអ៊ឹម ប៉ុន្តែភីនៅជាមួយគ្នាដែរ បានប៉ុន្មានខែភីនេះ រត់រួច រត់ទៅថៃ ដឹងខ្លួនៗ ភីដឹងខ្លួន។

ធានី ៖ ប៉ុន្មានខែ?

ថែវ ៖ បានម៉ាខែ ភីដឹងខ្លួនៗរត់ទៅថៃ។

ធានី ៖ តាអ៊ឹមនឹងនៅធ្វើជាថ្នាក់ពួកដដែល?

ថែវ ៖ អ៊ឹមៗនោះនៅធ្វើរហូត អ៊ឹម ខាត់ ឈ្មោះគ្នាវា មានអាអ៊ឹម អាខាត់ អាណាគេទៀតទេ ៣ នាក់ដែលក្តាប់សហករណ៍។

ធានី ៖ ចឹងកាលពេលពូរៀបការ៥៩គូហ្នឹង ខ្មៅហ្នឹង ជា?

ថែវ ៖ ជាប្រធានតំបន់។

ធានី ៖ ជាប្រធានក្នុងរោងការ?

ថែវ ៖ បាទ! ប្រធាន។

ធានី ៖ កាលហ្នឹងពូស្ម័គ្រចិត្តចូលរួមក្នុងការខ្លួនឯង ឬក៏ម៉េច?

ថែវ ៖ កាលនោះគេៗឲ្យជ្រើសរើសនារី យុវជនដែលជាប្រធានកងៗគេឲ្យឡើងចាប់ដៃៗយកគូយកគ្នាជាគូអនាគត។

ធានី ៖ ស្ម័គ្រចិត្តខ្លួនឯង?

ថែវ ៖ ស្ម័គ្រចិត្តខ្លួនឯង។

ធានី ៖ ហើយចឹងពូអ្នករើសគ្រួសារពូខ្លួនឯង?

ថែវ ៖ បាទ! រើសខ្លួនឯង។

ធានី ៖ ចឹងពូនៅពេលដែលពូផ្សឹក ធ្វើជាព្រះសង្ឃ ហើយផ្សឹកហ្នឹង គឺយើងស្ម័គ្រចិត្តផ្សឹក ឬមួយក៏យ៉ាងម៉េច?

ថែវ ៖ វាឲ្យយើងផ្សឹក បើកយើងមិនផ្សឹកអត់ចង្ហាន់ស៊ាប់ វាយើងអត់មានសម្រេចដូចវាបង្ខំឲ្យយើងផ្សឹក វាបិទចរាចរណ៍អត់ឲ្យអ្នកណានាំចូលចង្ហាន់ទៅប្រគេនលោក។

ធានី ៖ ពូអត់ចាំឈ្មោះអ្នកណាគេបង្ខំឲ្យពូផ្សឹកហ្នឹងទេនោះ?

ថែវ ៖ ទេ!

ធានី ៖ អ្នកដឹកនាំគេដែរ?

ថែវ ៈ ទេ! ម្ចាស់ស្រុកនោះឯង ។

ធានី ៈ ឈ្មោះអីគេ?

ថែវ ៈ ឈ្មោះៗឆាតនោះឯង ។

ធានី ៈ ឆាត?

ថែវ ៈ បាទ! ឆាត គណៈស្រុកហ្នឹងឯង ។

ធានី ៈ ឆាត គណៈស្រុកហ្នឹង?

ថែវ ៈ បាទ!

ធានី ៈ ជាអ្នកមកប្រកាស បង្ហូ?

ថែវ ៈ បាទៗ ប្រកាសមិនឲ្យយកចង្កាន់ទៅឲ្យលោកឆាន់ គេហៅពួកអាត្រងើល ។

ធានី ៈ ហើយពូដឹងថាមូលហេតុអីបានជាគេមិនឲ្យមានលោក មានវត្តមានអីចឹង?

ថែវ ៈ មិនដឹងទេ ។

ធានី ៈ ហើយកាលពេលពូមកចឹង វត្តអីនៅធម្មតាគេអត់មានវៃចោលទេ?

ថែវ ៈ បាទ! វត្តនេះយកអាសានីឈូសចោលអស់ កុដិដុតចោលអស់អាកុដិធំៗ ។

ធានី ៈ ហើយពូមានបានចូលក្នុងការរំលាយ កុដិ រំលាយវត្តអី?

ថែវ ៈ អូ! បានចូលរួមអី យើងនៅចល័ត ឃើញតែផ្សែង នៅចេះទៅស្រាប់តែទៅ ។

ធានី ៈ ដឹងថាហេតុអីបានគេដុតវត្ត ដុតអីមិនឲ្យមាន?

ថែវ ៈ មិនឲ្យមានបំបាត់សាសនាទាំងអស់ ព្រះវៃបំបាក់ចោលអស់ ព្រះវៃដាក់ខាងកើតថ្នល់ យក អាប៉ែនវិហារដែលឈូសឆាយបាន ដឹកវៃបំបែក រំលាយព្រះរំលាយអីក្រាលថ្នល់ វាមិនឲ្យ យើងមានជំនឿ អបិយជំនឿ មិនឲ្យយើងមានជឿទាំងអស់ ។

ធានី ៈ អត់ដឹងថាហេតុអី គ្រាន់តែដឹងថាគេបំបាត់សាសនា?

ថែវ ៈ បានល្មមបើនិយាយរួមគេថាល្មមគ្មានសាសនា ពួកនេះអត់មានជំនឿឲ្យយើងជឿអីទាំងអស់ ។

ធានី ៈ ចឹងព្រះសង្ឃដែលអត់ព្រមសឹក អត់មានអ្នកណាគេយកទៅសម្លាប់ណា គ្រាន់តែគេឲ្យយើង ផ្សឹកហើយ ចាត់តាំងទៅធ្វើការ?

ថែវ ៈ គ្រាន់តែគេឲ្យយើងទៅចាត់តាំងឲ្យយើងផ្សឹក ។

ធានី ៈ ចឹងក្រៅពីពូដែលធ្វើប្រធាន អ្នកផ្សេងៗគេធ្វើប្រធានដូចពូ ឬមួយក៏ធ្វើក្នុងកងចល័តព្រះ សង្ឃ?

ថែវ ៖ ព្រះសង្ឃៗដែលឈ្មោះ ពិលនេះ នៅក្នុងកងចល័តៗ ហើយឈ្មោះ ភិននេះមិនបានចល័ត ពេលដែលសឹកមកគ្នានៅក្នុងចល័តដែរ មិនបានប្រហែលជា២ខែគ្នាគាត់ឆ្កួត ។ វាស្តាយៗការ នៅជាសង្ឃស្តាយការសិក្សារៀនសូត្រ ដល់ឃើញបាត់សាសនាបាត់អស់ទៅមានគំនិតមួយ ដូចថាអារម្មណ៍មិនល្អ គាត់...ទៅជាឆ្កួតអស់បណ្តោយ ផាប់តាំង គេយកទៅវ៉ៃចោលតាំង កម្ទោះ ។

ធានី ៖ កាលនឹងគេយកគាត់យកទៅសម្លាប់ចោលឆ្នាំប៉ុន្មាន?

ថែវ ៖ គេយកទៅសម្លាប់ចោលក្នុងចន្លោះឆ្នាំ ប្អូននេះក្នុងចន្លោះឆ្នាំ៧៧នឹងឯង ។

ធានី ៖ ៧៧?

ថែវ ៖ បាទ! ៧៧ ។

ធានី ៖ ចុះពូបូតស្រូវឆ្នាំប៉ុន្មាន?

ថែវ ៖ ខ្ញុំបូតស្រូវ ដែលបូតស្រូវស៊ីចុងឆ្នាំ ដើមឆ្នាំ៧៧ ។

ធានី ៖ ដើមឆ្នាំ៧៧?

ថែវ ៖ បាទ!

ធានី ៖ ដើមឆ្នាំ៧៧ ពូមកបូតស្រូវនៅណាវិញ?

ថែវ ៖ បូតស្រូវខ្លួនឯង អាស្រូវធ្វើខ្លួនឯងការដ្ឋានយើង ប៉ុន្តែមានឈ្លបគេ គេដាក់ឈ្លបគេ ។

ធានី ៖ ដល់ពេលគេឃើញពូបូតចឹង?

ថែវ ៖ ឃើញគេបូតទៅគេចាប់ខ្ញុំចង ហើយអត់ឲ្យយើងនៅការដ្ឋាននឹងទេ បញ្ជូនទៅកន្លែងសហករណ៍ ទៅកសាងខ្លួន បញ្ជូនប្រុងទៅវ៉ៃចោល ដល់វាមានការតស៊ូច្រើនទៅ គេស្រណោះយើង បាន រួចជីវិត ។

ធានី ៖ ចឹងពូបូតស្រូវឈ្លប ពូចាំទេ?

ថែវ ៖ អត់ចាំ អត់ស្គាល់គេទេ ។

ធានី ៖ ប៉ុន្មាននាក់ ឈ្លបឃើញ?

ថែវ ៖ ឈ្លប៣នាក់ ។

ធានី ៖ ឈ្លប៣នាក់ ក្មេងៗដែរ?

ថែវ ៖ ឈ្លបចាស់ៗប្រហែលគ្នា ។

ធានី ៖ ប្រហែលៗគ្នា ឃើញពូក៏ចាប់ពូយកទៅដាក់ណា?

ថែវ ៖ គេមានក្វាវ មានដាវមួយទៀតនៅពីក្រោយ ។

ធានី ៖ ចាប់ពូយកទៅណាទៅ?

ថែវ ៖ ចាប់យកទៅភូមិតាខែត ។

ធានី ៖ ទៅភូមិតាខែត?

ថែវ ៖ ចង់ឆ្កាងទៅភូមិតាខែត ។

ធានី ៖ ភូមិតាខែត ចង់ឆ្កាងប៉ុន្មានថ្ងៃ?

ថែវ ៖ ចង់ម៉ាយប់ ។

ធានី ៖ ចង់ម៉ាយប់ ហើយយកទៅណាទៀត?

ថែវ ៖ ចង់ម៉ាយប់ បណ្ដើរខ្ញុំឲ្យទៅនៅចារលើ គេហៅឃុំ ចារលើដូចឃុំទឹកជោរ ។

ធានី ៖ ឃុំទឹកជោរ?

ថែវ ៖ បាទ!

ធានី ៖ ចឹងទៅភូមិចារលើហ្នឹង?

ថែវ ៖ បាទ!ទៅលើកដីនៅចារលើហ្នឹង ក្នុងម៉ាថ្ងៃគេឲ្យលើកឲ្យបាន៥ម៉ែត្រគីប ហើយគេលុត១០ថ្ងៃ លុតពលកម្ម១០ បើបានគ្រប់១០ថ្ងៃយើងអាចរស់ ។

ធានី ៖ លើកណាវិញ?

ថែវ ៖ លើកនៅភូមិចារ នៅខាងលិចភូមិចារ លើកព្រែកខាងលិចភូមិចារ ។

ធានី ៖ ហើយអ្នកណាគេអ្នកមើលពូពេលធ្វើអស់ហ្នឹង?

ថែវ ៖ ឈ្មោះវាអា ឈ្មោះវាភូមិចារ អូ!ដូចភ្លេចឈ្មោះៗថែនៗដូចជាស្លាប់ហើយមិនដឹងទេ ។

ធានី ៖ ថែន?

ថែវ ៖ ថែនមួយ អាមួយឈ្មោះថែន អាមួយឈ្មោះស្ដីខ្ញុំភ្លេចអាមួយនោះទៀត អានោះដើងកាច ឈ្មោះ.... ។

ធានី ៖ ថែនហ្នឹងគាត់មានងារជាអីបានមកមើលពូ?

ថែវ ៖ ថែននោះគេមើលអ្នកជាប់សន្តិសុខ ជាប់អ្នកទោស និយាយភាសាស្រួលស្ដាប់ ងាយស្ដាប់ ជាប់អ្នកដែលជាប់ទោស ។

ធានី ៖ ចឹងថែនហ្នឹងគាត់ធ្វើការនៅណាវិញ?

ថែវ ៖ ថែននៅខាងសហករណ៍គេ ។

ធានី ៖ សហករណ៍អីគេ?

ថែវ ៖ សហករណ៍...ចូលនេះ ។

ធានី ៖ គេហៅឈ្មោះ ឬក៏សន្តិសុខ?

ថែវ ៖ សន្តិសុខ ។

ធានី ៖ សន្តិសុខទឹកជោរ?

ថែវ ៖ បាទ! សន្តិសុខទឹកជោរ ។

ធានី ៖ ចឹងនៅទឹកជោរហ្នឹងមានសន្តិសុខមួយ?

ថែវ ៖ បាទ!

ធានី ៖ កន្លែងហ្នឹងគេហៅសន្តិសុខអីគេៗ សន្តិសុខស្រុក ឬក៏?

ថែវ ៖ សន្តិសុខសហករណ៍ ។

ធានី ៖ សន្តិសុខសហករណ៍?

ថែវ ៖ បាទ!

ធានី ៖ តែពូក្រែងពូទៅបូតស្រូវនៅ?

ថែវ ៖ ខ្ញុំបូតនៅកន្លែងនេះទេ ។

ធានី ៖ ហ្នឹងហើយដល់ពេលគេចាប់ៗយកទៅនោះ?

ថែវ ៖ គេចាប់យកទៅនោះ បូតនៅគល់រំចេក ។

ធានី ៖ ចុះពេលពូ ដល់ពេលពូដូចថាត្រូវបានគេលែងឲ្យលុតដំហើយ ពូថាចុះមកធ្វើនៅភ្នំលៀបចឹង?

ថែវ ៖ មើលដែលលុតដំខ្ញុំបាន១០ថ្ងៃ គេដឹងថាខ្ញុំលុតដំធ្វើការបានល្អគ្រប់ដែនការរបស់គេ ។ គេឲ្យបញ្ជូនខ្ញុំទៅនៅភ្នំលាប ខាងកើតភ្នំលាបគេហៅវាលរហាត់សួយ ។

ធានី ៖ គេនៅហ្នឹងធ្វើអីគេ ដាន់ស្រូវ?

ថែវ ៖ ដាន់ស្រូវឲ្យគេ ក្នុងម៉ោយប់ឲ្យបាន២ថាំង លុតឲ្យយើងម៉ោយប់ឲ្យបាន២ថាំង ។

ធានី ៖ ចុះបន្ទាប់មកពូថាអីអៀង ឡៃហៅពីត្រឡប់ទៅវិញ ត្រឡប់ទៅណាវិញ?

ថែវ ៖ អៀង ឡៃ បាត់ខ្លួន ប៉ុន្តែក្រោមអៀង ឡៃទៀត ឈ្មោះគឿន ។

ធានី ៖ គឿន?

ថែវ ៖ គឿន អានោះគឿនដែលចាប់សៀវហើយមានបងគឿងនោះ គេតែងតាំងជំនួសដែរគឿន ។

ធានី ៖ គឿនហ្នឹងងារជាស្អីគេ?

ថែវ ៖ គឿននោះ បើនិយាយរួមតំណាងឲ្យសៀវ បាត់សៀវ ចាប់សៀវទៅ ឡើងគឿនមួយទៀត ឡើងជុំនិរតីនោះឯងមើលការខុសត្រូវក្នុងការដ្ឋានខ្ញុំណា ។

ធានី ៖ ហើយពូទៅការដ្ឋានណា?

ថែវ ៖ អាការដ្ឋានចេកនោះឯង ។

ធានី ៖ ការដ្ឋានចេក?

ថែវ ៖ គោករំចេក ។ ដល់ពេលគៀននេះ បានគាត់យកកង់ទៅឌុបខ្ញុំពីភូមិចារលើ គេបញ្ជូនពីការដ្ឋានវាលរហាត់សួយខាងកើត អានេះប៉ុថែននេះយកខ្ញុំពីការដ្ឋានយកមកដាក់ចារលើ ។ អឺ! ត្រឹមចារលើនេះ បងនេះមិញ ។

ធានី ៖ បងគៀន?

ថែវ ៖ បងគៀនមកយកៗទៅ ។

ធានី ៖ យកពូទៅណា?

ថែវ ៖ យកមកផ្ទះវិញ ។

ធានី ៖ ដែលថាពូនៅការដ្ឋានត្រឡប់មកការដ្ឋានរំចេកនឹង គឺបន្ទាប់មកទៀតបានពូត្រឡប់មក?

ថែវ ៖ ខ្ញុំរត់មក ខ្ញុំលួចរត់មក ។

ធានី ៖ ចឹងកាលហ្នឹងពេលពូមកការដ្ឋានរំចេកធ្វើជាប្រធានយុវជនដែល?

ថែវ ៖ ខ្ញុំឈប់ហើយ ។

ធានី ៖ ចឹងគេហៅពូធ្វើអី?

ថែវ ៖ ដែលខ្ញុំ គេចាប់ខ្ញុំគឺខ្ញុំអស់អំណាចហើយ គេឈប់ជឿយើងហើយ ។

ធានី ៖ ចុះអាពេលតែគៀនហៅពូត្រឡប់មកការដ្ឋានរំចេក?

ថែវ ៖ មកៗឲ្យនៅជុំប្រពន្ធកូនវិញ ឲ្យនៅជុំប្រពន្ធខ្ញុំវិញ ប្រពន្ធខ្ញុំនៅនេះ ។

ធានី ៖ ដល់ពេលក្រោយទៀតបានពូនាំ១៥គ្រួសារហ្នឹងរត់ទៅ?

ថែវ ៖ បាទ! រត់មកផ្ទះ ។

ធានី ៖ ស្រុកកំណើត?

ថែវ ៖ មកស្រុកយើងនេះវិញ ។

ធានី ៖ រត់មកស្រុកកំណើតហើយ ម៉េចបានពូរត់មកស្រុកកំណើតចឹង?

ថែវ ៖ មើលវាអាចនឹងមិនរស់ វាថ្ងៃណាមួយនឹងអាចស្លាប់ដូចតែគេ ឃើញស្លាប់បន្តៗ ។

ធានី ៖ អូឃើញស្លាប់បន្តៗ?

ថែវ ៖ បាទ! ស្លាប់បន្តៗ ហើយប្រថុយប្រថានឲ្យមកដល់ស្រុកស្រែ ។

ធានី ៖ ចឹងពូថាមកដល់ស្រុកកំណើត គេឲ្យពូមកធ្វើប្រធានរោងបាយ?

ថែវ ៖ មកដល់ធ្វើរោងបាយ ។

ធានី ៖ អ្នកណាគេៗឈ្មោះអីគេ ដែលថាចាត់តាំងឲ្យពូធ្វើប្រធានរោងបាយ?

ថែវ ៖ ប្រធានរោងបាយ សំរើយ ។

ធានី ៖ សំរើយ?

ថែវ ៖ ឈ្មោះ សំរើយ ។

ធានី ៖ សំរើយហ្នឹងប្រធានរោងបាយធំ?

ថែវ ៖ សំរើយហ្នឹងគេខាង បើយើងហៅពាណិជ្ជកម្មគេ រោង ។

ធានី ៖ សំរើយៗហ្នឹងជនជាតិ ឬមួយខ្មែរយើង?

ថែវ ៖ ខ្មែរ ។

ធានី ៖ សំរើយហ្នឹងប្រធានពាណិជ្ជកម្ម?

ថែវ ៖ បាទ! ខាងអ្នកពាណិជ្ជកម្ម ។

ធានី ៖ ពាណិជ្ជកម្មសហករណ៍ហ្នឹង?

ថែវ ៖ សហករណ៍ៗ ។

ធានី ៖ សហករណ៍អីគេទៅ?

ថែវ ៖ សហករណ៍ថ្នាក់ពួកយើង ។

ធានី ៖ មិនមែនសហករណ៍ស្រុកយទេ?

ថែវ ៖ អឺ! ស្រុកយយើង ភូមិស្រុកយយើង សហករណ៍ភូមិស្រុកយ វាសាខាសហករណ៍បើនិយាយរួម វាពេញសហករណ៍ទេ គេហៅសាខា ។

ធានី ៖ ហើយពូថាគេឲ្យចំរាញម៉េច រើសម៉េច៤០គ្រួសារយកទៅហ្នឹង អ្នកណាគេបញ្ជាមក?

ថែវ ៖ អានេះគេ អ៊ីម ខាត់ៗ អាខាត់ អាអ៊ីមនេះ ដែលគេចំរាញ់គ្រួសារចំនួន៤០គ្រួសារនេះឲ្យទៅរៀនសូត្រផ្នែកកសិកម្ម ហើយក្នុងក្រុមនីមួយៗគឺមានក្រុមខ្លះមាន២ ក្រុមខ្លះមាន៣ ប៉ុន្តែដល់គេហៅខ្ញុំ គេយកឈ្មោះខ្ញុំ យកខ្ញុំទៅធ្វើស្រែ ដែលខ្ញុំទៅសាបឲ្យមកមើលឈ្មោះ ដែលគេមានបញ្ជីស្រេច តែបញ្ជីមិនដឹងគេស្រង់អីខ្លះ គ្រាន់តែឲ្យយើងមើលបញ្ជា តើក្នុងក្រុមមានឈ្មោះជម្លៀស ប្តុំអត់បើមានសូមឲ្យយើងទៅប្រាប់បងប្អូនឲ្យរៀបខោឲ្យរៀបគោរៀបក្របី រៀបអាវ រៀបដំឡូង រៀបស្អីពូជពង្សអីដាក់តាមរទេះទៅជាមួយ ។

ធានី ៖ អូ! ចឹងអ្នកជម្លៀស?

ថែវ ៖ បាទ! អ្នកជម្លៀស ។

ធានី ៖ អ្នកជម្លៀសមកពីភ្នំពេញអីហ្នឹង?

ថែវ ៖ ទេ! អ្នកជម្លៀសយើងស្រុកកំណើតនេះហើយ ជម្លៀសឲ្យទៅរៀនសូត្រ គេមិនបានហៅជម្លៀសទេ គេហៅយើងទៅរៀនសូត្រ សម័យនោះគេមិនបានហៅយើងជម្លៀសទេ ។

ធានី ៖ តែអ្នកណាគេ ដែលដូចថាត្រូវតែមានឈ្មោះទៅហ្នឹងអ្នកយ៉ាងម៉េចដែរ?

ថែវ ៖ អ្នកដែលត្រូវមានឈ្មោះ គេដាក់ប្រវត្តិអ្នកដែលជាប់និន្នាការនយោបាយ ធ្លាប់ធ្វើមេភូមិដែលយើងកាលនោះធ្លាប់ធ្វើជំទុក១ ធ្លាប់ធ្វើទាហាន ធ្លាប់ធ្វើមេ៥០ខ្នង ដែលហៅថាបម្រើនិន្នាការនយោបាយចាស់របស់របបលន់ នល់ ឬរបបរាជានិយមមុន ។

ធានី ៖ ឲ្យតែអ្នកធ្វើការ?

ថែវ ៖ អ្នកធ្វើការគេឲ្យយើងទៅរៀនសូត្រ ។

ធានី ៖ ចុះគ្រូបង្រៀនអីក៏យកដែរ?

ថែវ ៖ គ្រូបង្រៀនយកទាំងអស់ ឲ្យតែពាក់ព័ន្ធគ្រូបង្រៀន ពាក់ព័ន្ធប្រើអំណាចក្នុងសម័យមុន ។

ធានី ៖ ចុះអ្នកពីភ្នំពេញអីមកមានទេ?

ថែវ ៖ អ្នកពីភ្នំពេញមកមាន ។

ធានី ៖ មានត្រូវគេចាប់យកទៅ?

ថែវ ៖ មានមកអត់បានជម្លៀសទេ គេជម្លៀសមកនៅធម្មតា ។

ធានី ៖ តែគេមានហៅទៅដែរអត់?

ថែវ ៖ អត់បានហៅទេ ។

ធានី ៖ ហៅតែអ្នកដែលពាក់ព័ន្ធ?

ថែវ ៖ ហៅតែអ្នកមូលដ្ឋានចាស់ ។

ធានី ៖ ចុះអ្នកភ្នំពេញដែលជាប់ពាក់ព័ន្ធអីក៏អត់ហៅដែរ ហៅតែអ្នកមូលដ្ឋាន?

ថែវ ៖ អ្នកភ្នំពេញដែលជម្លៀសមកភ្នំពេញ នៅតាមភូមិយើងនោះនៅធម្មតាបានហើយ ។

ធានី ៖ ទោះជាគាត់ធ្វើការងារអីក៏ដោយ?

ថែវ ៖ ធ្វើស្រែធម្មតា បាទ!គេអត់ដឹងថាប្រវត្តិនោះគាត់ធ្វើអីទេ ។

ធានី ៖ បើសិនជាដឹង?

ថែវ ៖ បើដឹងអស់ ឲ្យទៅដូចគ្នា ។

ធានី ៖ ឲ្យទៅដូចគ្នា?

ថៃវ ៖ បាទ! នៅដូចគ្នា គេអត់ដឹងពួកយាយៗ ពួកថៃៗទាំងនោះមិនដឹងជា អត់ដឹងថាគាត់យកអ្នកបម្រើអីទេ។ បានថាអត់ដឹងប្រវត្តិ បើយើងស្រង់ប្រវត្តិចាស់គ្នាយើង គឺមានអ្នកណាទេមាន តែមេភូមិដែលថាទទួលខាងអ្នកស្រង់។

ធានី ៖ ចាំ! មេភូមិបានគេដឹង តែដឹងតែអ្នកភូមិយើងទេ?

ថៃវ ៖ បាទ! ចំពោះអាអ៊ីម អាខាត់ វាអត់ដឹងទេ ដូច្នេះគឺមានតែមេភូមិទេដែលស្រង់ឲ្យគេៗ។

ធានី ៖ កាលហ្នឹងមានប៉ុន្មានឃុំដែលស្រង់ឲ្យគេហ្នឹង ពូចាំទេ?

ថៃវ ៖ បាទ!

ធានី ៖ មានប៉ុន្មានភូមិដែលស្រង់ដូចពូដែរ?

ថៃវ ៖ ឈ្មោះៗស្រង់?

ធានី ៖ អឺ!

ថៃវ ៖ ឈ្មោះស្រង់ មានច្រើនណាស់។

ធានី ៖ ដូចថាមេភូមិណាខ្លះ គាត់អ្នកស្រង់ដូចពូដែរ ព្រោះកាលហ្នឹងពូត្រឹមប្រធានរោងបាយហ្នឹងដែរ គេហៅទៅ?

ថៃវ ៖ គេហៅទៅឲ្យយើងទៅសួរឈ្មោះក្នុងក្រុមយើង តើមានអ្នកត្រូវជម្លៀសដែរអត់។

ធានី ៖ អូ! ក្រុមយើង?

ថៃវ ៖ បាទ! ក្នុងក្រុមយើង។

ធានី ៖ តែគេហៅម៉ាក្រុមៗទេ?

ថៃវ ៖ បាទ! គេហៅម៉ាក្រុម សួរក្នុង។

ធានី ៖ តែក្រុមពូមានគ្នាប៉ុន្មាន?

ថៃវ ៖ គ្នា បើគិតទៅវា២០គ្រួសារ។

ធានី ៖ ២០គ្រួសារ?

ថៃវ ៖ ២០គ្រួសារបង្កើតជារោងបាយមួយ។

ធានី ៖ រោងបាយទី៧?

ថៃវ ៖ បាទ! រោងបាយទី៧។

ធានី ៖ ចឹងគេឲ្យពូមកមើល?

ថៃវ ៖ មើលក្នុង២០គ្រួសារមានឈ្មោះក គ្រួសារនេះឯងមានប្ដីធ្វើអីខ្លះចង់ដឹង។

ធានី ៖ ហើយពូទៅសួរគេ ឬមួយក៏គេឲ្យមើលហើយៗ?

ថែវ ៈ បញ្ជីគេមានស្រេច ។

ធានី ៈ ចុះម៉េចពូដឹង គ្រួសារហ្នឹងថាធ្វើអី ៗ ?

ថែវ ៈ ព្រោះយើងដឹងភូមិយើង ដែលយើងមិនដឹងក្នុងប្រវត្តិក្នុងភូមិយើង ព្រោះធ្វើយើងអ្នកណាធ្វើអីក៏យើងដឹង ។ សូម្បីតែក្នុងសព្វថ្ងៃអ្នកពីមុនឪវាធ្វើអីខ្លះយើងដឹង ចឹងយើងអាចដឹងបាន យើងអាចដឹងថាគ្រួសារនេះមិនដែលធ្វើទាហានទេ គ្រួសារនេះមិនដែលធ្វើមេភូមិទេ ។

ធានី ៈ ចឹងកាលហ្នឹងទៅ ៗ ៤០ នាក់?

ថែវ ៈ ៤០ គ្រួសារ ។

ធានី ៈ ទៅអ្នកធ្វើការងារអីខ្លះ ពូដឹងទេ?

ថែវ ៈ ត្រឹមមេភូមិ ត្រឹមមេ៥០ខ្នង ។

ធានី ៈ ទៅទាំងគ្រួសារម៉ង?

ថែវ ៈ ទៅទាំងគ្រួសារទាំងអស់ ។

ធានី ៈ ៤០ ហ្នឹង៤០ នាក់ ឬ៤០ គ្រួសារ?

ថែវ ៈ ៤០ គ្រួសារ មិនតិចទេ ។

ធានី ៈ ហើយម៉េចបានពូដឹងថាគេហៅយកទៅសម្លាប់?

ថែវ ៈ ដឹង ចន្លោះក្នុងល្ងាចនោះគោក្របីរត់មកវិញ វាយកទៅដល់សាលាកាលេះយើងនេះ វាវៃមនុស្ស ស្រាប់តែគោក្របីវាចងអាខ្លះចងវាដាច់មកផ្ទះ វារត់មកផ្ទះវិញ ។ ដូច្នេះវាបងប្អូនដែលអ្នកថ្មពួកនោះ គេឲ្យដំណឹងមកថាបងប្អូនដែលយកទៅស្លាប់ទាំងអស់ ។

ធានី ៈ គេប្រាប់ដំណឹងដែរ?

ថែវ ៈ ប្រាប់ដំណឹង ព្រោះវាអត់បានទៅមុខហ្នឹងគេទេ គេសម្លាប់ចោលដាក់នឹងអណ្តូងនោះអស់ ។

ធានី ៈ ដាក់នៅអណ្តូងនៅសាលាកាលេះ?

ថែវ ៈ អណ្តូងសាលាកាលេះ ។

ធានី ៈ រាល់ថ្ងៃមានទេ?

ថែវ ៈ អណ្តូងគេកាយនៅសម័យរដ្ឋកម្ពុជា កាយយកមាសយកម៉ត់ យកខ្មោចយកដុតៗអស់ ។

ធានី ៈ អណ្តូងហ្នឹងធំទេ?

ថែវ ៈ អណ្តូងធំណាស់ អណ្តូង ។

ធានី ៈ ហើយគេកាយៗយកទាំងអស់?

ថែវ ៈ បាទ! ខ្មោចមានណាម៉ាភូមិស្វាយនេះ ថ្មពួកគេជម្លៀសយកទៅវៃចោលទាំងអស់ ។

ធានី ៖ តែក្នុងអណ្តូងមួយ?

បែវ ៖ ក្នុងយប់ មួយៗ ម៉ាល្ងាចវ៉ៃទាំងអស់ណាត់ជាមួយគ្នាទាំងអស់ ។

ធានី ៖ ចឹងពូ ចុះពូថាពូរត់ទៅថៃឆ្នាំប៉ុន្មាន ចាំទេ កាលហ្នឹង?

បែវ ៖ ឆ្នាំ៧៧ ខែ៧ ដែលខ្ញុំរត់ទៅថៃ ។

ធានី ៖ ចុះគេហៅពូទៅសួរហ្នឹងនៅឆ្នាំប៉ុន្មាន ៧៧ហ្នឹង?

បែវ ៖ បាទ!

ធានី ៖ គេហៅពូទៅសួរដែលថាប្រជាជនយើង?

បែវ ៖ ដែលជម្លៀសនោះ ៧៧ដែល តែនៅក្នុងខែ៥ ។

ធានី ៖ ចឹង៧៧ខែ៧ពូរត់ទៅថៃ?

បែវ ៖ បាទ!

ធានី ៖ កាលហ្នឹងម៉េចបានពូមានគំនិតចង់រត់ទៅថៃ?

បែវ ៖ ដោយសារផ្អើលអាសម្លាប់នេះ ខ្លាចស្លាប់នេះ ។

ធានី ៖ ខ្លាចស្លាប់នឹងដែរ?

បែវ ៖ បាទ! ខ្លាចស្លាប់ ។

ធានី ៖ ហើយទៅជាមួយគ្រួសារ២៥នាក់ហ្នឹង អ្នកណាគេខ្លះជាខាងណាខាងណែខ្លះបានរត់ទៅ?

បែវ ៖ ម៉ានេះមកនៅទេ ទៅភូមិយើងនេះខ្លះភូមិយើងអ្នកតានេះខ្លះអាភូមិជាប់ ។

ធានី ៖ ដូចថាមានអ្នកណាផ្តើមគំនិតបានចង់រត់ទៅថៃ?

បែវ ៖ មាន ។

ធានី ៖ អ្នកណាគេដែរ?

បែវ ៖ នេះឯង ពួកគាត់នោះគាត់ធ្លាប់ធ្វើឈ្លបឲ្យខ្មែរក្រហមៗ ឬក៏ធ្វើបម្រើនិន្នាការខ្មែរក្រហមធ្លាប់
បានដឹងថាប្រវត្តិពួកនេះសម្លាប់គៗគ្នា វាខាងក្រោយស្លាប់ដល់ពួកវា ។

ធានី ៖ ចឹងពួកគាត់ឈ្មោះអីគេ ដែលផ្តើមគំនិតរត់ហ្នឹង?

បែវ ៖ ដេង អួង ។

ធានី ៖ ដេង អួង?

បែវ ៖ បាទ!

ធានី ៖ ដេង អួងហ្នឹងគាត់ឈ្លបហ៎?

បែវ ៖ ឈ្លបៗ ។

ធានី ៖ ឈប់ៗឃុំ?

ចែវ ៖ ឈប់ៗស្រុក ។

ធានី ៖ ឈប់ស្រុក?

ចែវ ៖ បាទ!

ធានី ៖ ចឹងគាត់ធ្វើការនៅមន្ទីរសាលាកាលេះហ្នឹងដែរ?

ចែវ ៖ បាទទេ! នៅខាងនេះឯង ។

ធានី ៖ ឈប់ស្រុកហ្នឹង គេធ្វើការខាងអីគេ?

ចែវ ៖ គាត់នេះ បើត្រូវវៃតានេះឯងតាកំពុងអន្តុយសម្ភាសន៍នេះឯង គាត់យោធាប្រចាំសន្តិសុខ ។

ធានី ៖ យោធាសន្តិសុខ?

ចែវ ៖ យោធាសន្តិសុខ ។

ធានី ៖ ប្រចាំ?

ចែវ ៖ ប្រចាំស្រុកថ្មពួក ។

ធានី ៖ ប្រចាំស្រុកថ្មពួក?

ចែវ ៖ អឺ!

ធានី ៖ ចឹងកន្លែងនេះគេហៅយោធា មន្ទីរសន្តិសុខថ្មពួក?

ចែវ ៖ បាទ! ថ្មពួក ។

ធានី ៖ ចឹងហេងអួងហ្នឹង គ្រាន់តែ?

ចែវ ៖ ហេង អួង គ្រាន់តែឈប់នៅក្រៅទេ ឈប់ស្រុក ។

ធានី ៖ ឈប់ស្រុកថ្មពួក ប៉ុន្តែអត់បានធ្វើការនៅក្នុងមន្ទីរហ្នឹងទេ?

ចែវ ៖ នៅមន្ទីរការចាប់វៃទេ ។

ធានី ៖ ហេង អួងហ្នឹង គាត់នៅរស់ទេ សព្វថ្ងៃ?

ចែវ ៖ នៅរស់ ។

ធានី ៖ នៅរស់នៅណាវិញ?

ចែវ ៖ នៅរស់តើ នេះនៅភូមិត្បូង ។

ធានី ៖ ភូមិត្បូង នៅជាមួយភូមិពូដែរ?

វែង ៖ ភូមិស្វាយយើងនេះឯង នៅចុងភូមិនេះ ។

ធានី ៖ ចឹងពូរត់ទៅជាមួយគាត់?

ថៃវ ៖ រត់ជាមួយគាត់ ។ គាត់អ្នកប្រាប់ខ្ញុំថានៅមិនបានទេ ថ្ងៃណាស្លាប់ម៉ាខ្លៃ ថ្ងៃណាសម្លាប់ឯង ។

ធានី ៖ អូ! គាត់ប្រាប់គ្នា?

ថៃវ ៖ បាទ! ប្រាប់ៗខ្ញុំ បើសិនជាយើងមិនរត់ ថ្ងៃណាដល់យើងម្ដងហើយ វាសម្លាប់បន្ដៗ ដឹងខ្លួនក៏ដល់ថ្នាក់ធ្វើបម្រើការងារប្រធានកងគេផង ថ្ងៃណាដល់ឯងម្ដងហើយ ក្ដុច ។

ធានី ៖ ចុះមែន ហ៊ុនដែលប្រធាននារីហ្នឹង នៅខាងណាវិញរាល់ថ្ងៃ?

ថៃវ ៖ នៅខាងត្បូងចុង ។

ធានី ៖ នៅស្វាយ ក្បែរគ្នា?

ថៃវ ៖ បាទ! ក្បែរគ្នា បងខ្ញុំ ។

ធានី ៖ ម៉ែន ហ៊ុនហ្នឹង?

ថៃវ ៖ បាទ! បងជីដូនមួយ ។

ធានី ៖ បងជីដូនមួយ?

ថៃវ ៖ បាទ!

ធានី ៖ ដល់ពេលហេង អួងហ្នឹង ត្រូវបងប្អូនពូដែរ?

ថៃវ ៖ ហេង អួង អ្នកឆ្ងាយតិចហើយ មិនមែនជាបងប្អូនដាច់ឆ្ងាយគ្នាគ្រាន់ហើយ ។

ធានី ៖ ចឹងគាត់នាំពូរត់ទៅថៃ ពេលរត់ទៅថៃហ្នឹង យ៉ាងម៉េចដែរ ជួបប្រទះអីខ្លះ?

ថៃវ ៖ ជួបថៃវាធ្វើបាប គ្រាន់ថាគេគំរាមយើង មុនដំបូងគេពិសោធន៍យើង បើសិនយើងស្មោះត្រង់គេរត់ៗទៅដោយស្មោះត្រង់គេធ្វើបាបយ៉ាងណាយើងស៊ូ
តែបើយើងទៅបន្ទំៗយើងរត់មកគេ បាញ់យើងចោល ។ ដូច្នេះ យើងក្នុងនាមយើងថា បើទៅហើយត្រូវតែ បើថៃស្លាប់ថា ស្លាប់ៗចុះ ដាច់ចិត្តថាមកវិញក៏មិនរស់ មិនដឹងជារស់បែបណា ។

ធានី ៖ ចឹងការរត់ទៅថៃហ្នឹងរត់តាមច្រកណា?

ថៃវ ៖ បឹងអំពិល ។

ធានី ៖ បឹងអំពិល?

ថៃវ ៖ ដំរំគេហៅបឹងអំពិល ។

ធានី ៖ ដំរំអំពិល?

ថៃវ ៖ កាលនោះទៅនៅព្រៃ កន្លែងខ្មែរក្រហមនៅ ទៅផុតអា ។

ធានី ៖ ចុះពូទៅមិនមានកងទ័ពខ្មែរក្រហមការពារ?

ថែវ ៖ ទៅៗយប់ ។

ធានី ៖ ទៅយប់ ចុះពូស្គាល់ភូមិហ្នឹងច្បាស់ ផ្លូវចូល?

ថែវ ៖ មានអ្នកនាំផ្លូវម្នាក់ អ្នកស្រុកកំណើតនៅស្រែល្អ នៅតាស៊ុំនៅស្រុកតាស៊ុំគេដឹងផ្លូវធ្លាប់ឃ្វាល ក្របី ធ្លាប់ដឹងថាត្រង់នេះភូមិស្រង៉ែ ត្រង់នេះតាប់ផ្សា វាដឹងអស់ ដល់យើងវត់ទៅវាដឹងច្រក ល្អក ។

ធានី ៖ គាត់ឈ្មោះអីគេ?

ថែវ ៖ ឈ្មោះវ៉ាត់ ។

ធានី ៖ វ៉ាត់អីគេវ៉ាត់?

ថែវ ៖ អីគេវ៉ាត់ ខ្ញុំស្គាល់ ។

ធានី ៖ គ្រាន់ដឹងថាអ្នកភូមិល្អ?

ថែវ ៖ បាទ! អ្នកភូមិគេហៅភូមិតាស៊ុំ គ្នាគេវត់ដឹងផ្លូវ ។

ធានី ៖ ហើយពូវត់ទៅដល់ថៃ តាមច្រកស្អីគេ?

ថែវ ៖ ចូលភូមិស្រង៉ែ ចំស្រង៉ែតែម្តង ។

ធានី ៖ ភូមិស្រង៉ែ?

ថែវ ៖ បាទ! ស្រង៉ែថៃ ។

ធានី ៖ ពូថាខត្តរមានជ័យយើង?

ថែវ ៖ ទេ! ស្រង៉ែថៃ ។

ធានី ៖ អូ! ភូមិស្រង៉ែថៃ?

ថែវ ៖ បាទ! ស្រង៉ែស្រុកថៃ ។

ធានី ៖ ក្នុងខេត្ត ឬឃុំអីដែរ?

ថែវ ៖ ភូមិស្រង៉ែ ឃុំម្កាក់ ។

ធានី ៖ ម្កាក់យើងនេះ?

ថែវ ៖ ទេ! ម្កាក់គេម្កាក់ថៃៗ ។

ធានី ៖ ចឹងយើងក៏មាន គេក៏មាន?

ថែវ ៖ យើងម្កាក់មាន គេក៏មាន ម្កាក់ស្រុកគេភូមិតាប់ផ្សា អំភើបតាប់ផ្សា ។

ធានី ៖ ដល់ពេលខេត្តៗស្រះកែវ?

ថែវ ៈ ខេត្តពីមុនមិញគេហៅភៈជិន សព្វថ្ងៃគេបំបែកខេត្តដូចយើងចេះឯង គេដាក់ស្រះកែវ ពីដើមមិញស្រះកែវៗកោះភ្លូ នៅស្រុកនេងដើមស្រះកែវ ។ កាលខ្ញុំរត់ទៅនៅស្រុកនៅឡើយ ។

ធានី ៈ ស្រុកផ្សា ឃុំផ្សា ឃុំអីគេដែល ភូមិស្រង៉ែ?

ថែវ ៈ ភូមិស្រង៉ែ ។

ធានី ៈ ឃុំ?

ថែវ ៈ ឃុំម្កាក់ ។

ធានី ៈ ស្រុកផ្សា?

ថែវ ៈ ស្រុកតាប់ផ្សា ។

ធានី ៈ ដល់ពេល?

ថែវ ៈ កាលនោះខេត្តៗប្រាក់ជិនបូរី ។

ធានី ៈ ប្រាក់ជិបបូរី ដល់ពេលឥឡូវគេបំបែកជាស្រះកែវ?

ថែវ ៈ បំបែកជាស្រះកែវ ។

ធានី ៈ ពេលពូរត់ទៅហ្នឹង ទៅដល់ដីថៃ ទាហានថៃចាប់យកតែម្តង?

ថែវ ៈ ចាប់ៗបាទ! ចាប់ ។

ធានី ៈ ស្គាល់ឈ្មោះអ្នកចាប់ហ្នឹងទេ ទាហានថៃ?

ថែវ ៈ អត់ស្គាល់ៗទេ ។

ធានី ៈ ហើយនៅហ្នឹងប៉ុន្មានខែ បាន?

ថែវ ៈ នៅមិនបានម៉ាខែទេ នៅបានម៉ាថ្ងៃ ។

ធានី ៈ នៅបានម៉ាថ្ងៃ?

ថែវ ៈ បានម៉ាថ្ងៃគេបញ្ជូនមករោងជាត់តាប់ផ្សា ។

ធានី ៈ ទ្រង់ជាត់តាប់ផ្សាហ្នឹង កន្លែងអីគេ?

ថែវ ៈ រោងជាត់គេ កន្លែងគេដាក់មនុស្ស ។

ធានី ៈ ចឹងនៅហ្នឹងមានខ្មែរច្រើនរត់ទៅដូចជាពូរត់ទៅដែរ?

ថែវ ៈ គេទើបតែរៀបចំ ទៅដល់អន្តរជាតិប្រកាសវា មុនដំបូងវាសម្លាប់ខ្មែរចោលអស់ ទៅហ្នឹងវាសម្លាប់ៗអត់មានទុកទេ ។ ដល់ក្រោយមកអន្តរជាតិដឹង អន្តរជាតិសុំឲ្យថៃឈប់សម្លាប់ខ្មែរ ។

ធានី ៈ មានដែរពូ អ្នកដែលរត់ទៅសម្លាប់?

ថែវ ៖ អឺ! មានផ្លូវៗដូចជីឡូង វាបន្លាញរោងខ្មោច នេះរោងជីឡូងរោងគោយើងនេះ សុទ្ធតែពួកខ្មោចខ្មែរ ខ្មោចមែនៗ

ធានី ៖ គេប្រាប់ចឹងម៉ង?

ថែវ ៖ បានថាឈប់សម្លាប់ដែលបាន១០ថ្ងៃ ដែលបិទឈប់សម្លាប់ សំណាងហើយបងឯងដែលមកនេះគេទើបតែ ស្តេចថៃប្រកាសឲ្យឈប់សម្លាប់ខ្មែរ១០ថ្ងៃនេះៗ

ធានី ៖ ហើយសម្លាប់ខ្មែរប៉ុន្មាននាក់ពូដឹងទេ?

ថែវ ៖ មិនទាន់បាត់ធុំក្លិនអាឆាបអត់ ទាន់បាត់ផង និយាយទៅបន្លាញយើងឃើញម៉ង នាំគ្នាចងយើង ទៅដល់វាស្រាយមើល នេះសុទ្ធតែខ្មោចខ្មែរៗ

ធានី ៖ ប៉ុន្មាននាក់ពូដឹងទេ?

ថែវ ៖ រាប់រយនាក់ៗម៉ាខ្សែហ្នឹងមានផ្ទាយមួយដែលគាត់នៅរស់ ម៉ាខ្សែ១០០នាក់ សម្លាប់កាច់គាត់រត់មកវិញ បានមួយ រត់រស់បានមួយដាច់ខ្សែ គាត់រត់ផុតទៀត នេះឈ្មោះផ្ទាយនៅភូមិបាសិត គាត់រស់នេះថៃសម្លាប់ គាត់មកមុនខ្ញុំប្រហែល១០ថ្ងៃ មុនទើបបានឈប់ៗ

ធានី ៖ ដល់ពេលពូទៅនៅហ្នឹងបានប៉ុន្មានខែ បានពូថារត់មកវិញ?

ថែវ ៖ ខ្ញុំនៅបានដាងម៉ាឆ្នាំ ជិត២ឆ្នាំៗ

ធានី ៖ ចឹង៧៩ពូរត់ម៉ង?

ថែវ ៖ បាទ!

ធានី ៖ ព្រោះពូថា៧៧បានរត់?

ថែវ ៖ ៧៧ខ្ញុំរត់ៗ

ធានី ៖ ៧៧ពូរត់ទៅថៃ?

ថែវ ៖ ៨០បានខ្ញុំមកវិញ បាន២ឆ្នាំៗ

ធានី ៖ ៧៧ពូរត់ទៅថៃ?

ថែវ ៖ អឺ! ដើម៧៧ ខែ៧ រត់ទៅថៃៗ

ធានី ៖ ហ្នឹងរត់ទៅថៃ?

ថែវ ៖ បាទ! ហ្នឹងៗ

ធានី ៖ ៧៨?

ថែវ ៖ ៧៨ក៏នៅថៃៗ

ធានី ៖ ៧៨នៅថៃ?

ថែវ ៖ បាទ! ៧៩ក៏ខ្ញុំនៅថៃ ។

ធានី ៖ ក្រែងពូថានៅ?

ថែវ ៖ ៨០ បានខ្ញុំមកវិញ នៅ៣ឆ្នាំហ្នឹង ខ្ញុំនៅយូរ ។

ធានី ៖ ចឹង៨០ បានពូត្រឡប់មកវិញ?

ថែវ ៖ បាទ! ៨០ ៗ មកវិញ ។

ធានី ៖ ហើយពូមកវិញ បានពូធ្វើមេភូមិ?

ថែវ ៖ មកវិញ ខ្ញុំមកវិញមិនទាន់បានដល់មេភូមិ ធ្វើមេក្រុមៗក្តាប់ក្រុមនៅប្រហែលជាកន្លះឆ្នាំបាន ធ្វើអនុភូមិ ។ បានបន្តមកទៀតគេឲ្យធ្វើមេភូមិ ។

ធានី ៖ កាលពេលពូនៅ ពូថាម៉េចទ័ពខ្មែរក្រហមម៉េច ទ័ពប៉ាវ៉ាម៉េច?

ថែវ ៖ ដល់ពេលនោះសម័យយើងតំបន់នេះកើតតំបន់តស៊ូហើយណា វាមានទ័ពខ្មែរក្រហមៗ វាមាន ទ័ពប៉ាវ៉ាៗខាងសឹនសាន មានប៉ាវ៉ាខាងសីហនុ ។ ដូច្នេះពេលដែលប៉ាវ៉ាវាចុះមករកអង្ករមក ដេកតាមព្រៃ មកចុះមកក្រោមមក វាមកសុំស្បៀងៗស៊ីវាមកទាក់ទងតាមរយៈភូមិ ។ ដូច្នេះ តាមរយៈភូមិនេះ គឺទាក់ទងមេភូមិសុំឲ្យរាយអង្ករឲ្យវា ។

ធានី ៖ ប្រាប់មេភូមិម៉ង?

ថែវ ៖ បាទ! មកប្រាប់មេភូមិ វាផ្ញើសំបុត្រ ។

ធានី ៖ អត់ទេ ចង់និយាយថា ដំបូងអត់ទេ ពូអត់ទាន់ធ្វើការតាមគេទេ ឬក៏ធ្វើតាមគេតាំងពីដំបូងមក ហើយ?

ថែវ ៖ យើងធ្វើតាមតាំងពីមេភូមិចាស់ៗគេធ្វើបានមុន ដូច្នេះមេភូមិចាស់គេចាប់ដាក់គុក ហេងសំរិន គេចាប់ដាក់គុក គេថាយើងឲ្យអង្ករខ្មាំង យើងមិនចេះមានល្បិចរាយការណ៍ឲ្យគេ ។

ធានី ៖ ចាប់ពូដែរ ចាប់មេភូមិចាស់?

ថែវ ៖ ចាប់មេភូមិចាស់ ។

ធានី ៖ ហើយបានពូឡើង?

ថែវ ៖ បាទ! ឡើង បាទ ខ្ញុំឡើងដល់ចាប់ឡើងទៅ គាត់អត់មានល្បិចរាយការណ៍ ដូនថ្ងៃណាខ្ញុំល្បិច ខ្ញុំច្រើន ល្បិចខ្ញុំរស់ ថ្ងៃណាខ្ញុំណាត់គ្នាថ្ងៃបាញ់ៗគ្នាហ្នឹង ប៉ុន្តែបាញ់ទៅលើទេ គ្រាន់តែបាញ់ ទៅឲ្យវាទម្លាក់សាក់កាដូ ទម្លាក់តែអង្ករទៅ យើងយកទៅរាយការណ៍ប្រាប់ជំនាញការយួន

ថានេះខ្ញុំយប់មិញ ប៉ាវ៉ាចូលយកអង្ករខ្ញុំស្ទាក់បាញ់ធ្លាក់តែអង្ករ តាមពិតយើងដឹកអង្ករឲ្យគេបាត់ហើយ ល្បិចដូច្នេះថាយើងតស៊ូជាមួយគេ ។

ធានី : ចឹងពូបានរៀបជាកងសេនាជនអីភូមិដែរ?

ថៃវ : សេនាជនៗ បាទ!សេនាជន មានអាវុធ ខ្ញុំមានអាវុធកាន់ ។

ធានី : ហើយតាមការពិតយើងអត់បានធ្វើអីទេ គ្រាន់យើង?

ថៃវ : ធ្វើអីទេ គ្រាន់តែល្បិចគ្នា យើងនិយាយគ្នាស្រេច ។

ធានី : ចឹងខាងខ្មែរក្រហមក៏ចឹងដែរ?

ថៃវ : ខ្មែរក្រហមដូចគ្នា ។

ធានី : ខ្មែរក្រហមចូលមកដូចថាចូលមកដែលចាល់គ្នាទេ?

ថៃវ : ចូលមកខ្ញុំឲ្យគេរាយកងគ្នា ឲ្យគេដើររាយកងវា ឈ្លបខ្ញុំនៅ......ដល់ពេលណាត់ចេញផុតប្រហែលជាឆ្ងាយទៅយើងបាញ់ទៅលើ គេបាញ់មកលើ ឲ្យវាទម្លាក់សាកាដូឲ្យខ្ទះ យើងយកអាហ្នឹងទៅរាយការណ៍ឲ្យជំនាញការយួន វាបែកខ្ទេកបានរស់ ត្រឹមរស់ ។

ធានី : ចឹងពូដែលចាល់គ្នារវាងប៉ាវ៉ា ខ្មែរក្រហមចូលមកភូមិក្នុងពេលតែមួយអីចឹងមានទេ?

ថៃវ : មានៗ ។

ធានី : ចឹងធ្វើម៉េចទៅ?

ថៃវ : កាលនោះដើម្បីយើងនៅក្នុងព្រៃក្រោមវាត្រូវគ្នា វាអត់ទាស់ប៉ុន្មានទេ ។

ធានី : ចឹងប៉ាវ៉ាខ្មែរក្រហម?

ថៃវ : បាទ! អាប៉ាវ៉ាខ្មែរក្រហមខ្លះត្រូវគ្នា អាប៉ាវ៉ាខ្មែរក្រហមអត់ត្រូវគ្នាទេ ។

ធានី : ចឹងម៉េចពូដឹងថាអ្នកណាប៉ាវ៉ា អ្នកណាខ្មែរក្រហម?

ថៃវ : ខោអាវខុសគ្នា ។

ធានី : អូ! គេពាក់ខោអាវខុសគ្នា?

ថៃវ : អឺ! ឯកសណ្ឋានខុសគ្នា ។

ធានី : ដល់ពេលគេចូលមកក្នុងភូមិពូ មានគេបាញ់គ្នាក្នុងភូមិអីទេ?

ថៃវ : មិនដែលបាញ់ទេ ។

ធានី : មិនដែលទេ?

ថៃវ : អឺ! ដែលបាញ់ៗខាងក្រៅ ។

ធានី : ចាល់គ្នាអី?

ថែវ ៖ ចាល់គ្នាបានបាញ់ គេមានបាញ់គ្នាម្តង បាញ់នៅភូមិវាលត្រាច បាញ់គ្នាម៉ាថ្ងៃវល់ល្ងាច ខ្មែរក្រហមប៉ាវ៉ា ។

ធានី ៖ ហើយយើងអ្នកនៅក្នុងភូមិហ្នឹងធ្វើម៉េចទៅ?

ថែវ ៖ យើងចាំតែស្តាប់សូរគេទៅ ខាងនោះប៉ាវ៉ាស្លាប់អស់៣នាក់ ។

ធានី ៖ ហើយមានដីករណ្តៅត្រង់សេរអីដែរ?

ថែវ ៖ ដីក តាមភូមិដីក ចាំរហូត ។

ធានី ៖ អត់មានពេលចូលមកចឹង?

ថែវ ៖ ខ្ញុំឆេះផ្ទះអស់ ឆេះផ្ទះខ្ទេចអស់រលីង បេបាញ់ថ្មពួកនោះ បេវាធ្លាក់មកចំកណ្តាលផ្ទះ ខ្ទេចផ្ទះខ្ញុំអស់រលីង ។

ធានី ៖ ពូចេះរាយការណ៍បានរស់?

ថែវ ៖ ហ្នឹងបានរស់ ។

ធានី ៖ ដល់ពេលចឹងពូធ្វើមេភូមិរហូតដល់ឆ្នាំ?

ថែវ ៖ ៩០ ។

ធានី ៖ ៨៨ ៨៩?

ថែវ ៖ អឺ! ៨៨ ៨៩ ។

ធានី ៖ បានពូចាប់ផ្តើមធ្វើ?

ថែវ ៖ នគរបាល ។

ធានី ៖ នគរបាលឃុំ?

ថែវ ៖ នគរបាលឃុំ បានម៉ាឆ្នាំជាង ។

ធានី ៖ ធ្វើអីខ្លះទៅ?

ថែវ ៖ នគរបាលឃុំយើងធ្វើនគរបាលត្រឹមតែ យើងមើលដូចថា ។

ធានី ៖ ព្រោះកាលហ្នឹងវានៅសម័យតស៊ូដែរ?

ថែវ ៖ សម័យតស៊ូ យើងមើលតាមភូមិមើលសន្តិសុខ ។

ធានី ៖ នៅតែមានការ មានប៉ាវ៉ា មានខ្មែរក្រហមអីចឹង?

ថែវ ៖ មានចាប់មានចង មានបណ្តាញខ្មាំងអីចេះចាប់អីខ្លះទៅ ប៉ុន្តែយើងចាប់ដើម្បីយើងមានខ្មែរគ្នាយើងផង មិនមែនយើងបម្រើយួននៅជាមួយយើង ក៏យើងមានល្បិចរត់ ។

ធានី ៖ ចឹងពូចាប់ខ្មែរក្រហមដែលរត់នៅក្នុងជុំយើងហ្នឹងដែរ?

ថៃវ ៖ ឧបមាថាខ្មែរក្រហម ឬក៏ប៉ាវ៉ា មានចង់ទៅលេងស្រុកៗ យើងជួយៗធ្វើលិខិតចេញទៅស្រុក ដូច្នេះជំនាញការនៅនោះ យើងដាក់ថាពួកនេះស្រេចយើងនិយាយអត់ដឹងទេ ល្បិចយើងជួយ ដើម្បីឲ្យគ្នាយើងរស់ គឺយើងជួយគ្នាយើង ។ ខ្ញុំជួយបានកំប៉េសពួកកងពលៗ ។

ធានី ៖ កងពលអីគេពូ?

ថៃវ ៖ កងពលង-៧១ ។

ធានី ៖ ង-៧១ខាងណាវិញ?

ថៃវ ៖ ខាងរដ្ឋកម្ពុជា ។

ធានី ៖ ខាងរដ្ឋកម្ពុជា?

ថៃវ ៖ វាដល់ពេលវាទៅនៅព្រៃវាខ្លាចប៉ាវ៉ា វាខ្លាចខ្មែរក្រហមរត់ចូលស្រុកវិញៗ ដើម្បីជួយវាវិធី ជួយយើងដាក់តែភូមិយើង ស្រុកយើង ព្រោះយើងធ្វើនគរបាលកាលនោះផ្នែកក្រសួងមហា ផ្ទៃ អ្នកចេញសំបុត្រចេញស្នាម អនុញ្ញាតិឲ្យ មានតែនគរបាលទេដែលមានសិទ្ធិចេញសំបុត្រ ចេញចូលបាន ។

ធានី ៖ ចឹងខាងខ្មែរក្រហមអីដែលធ្លាប់មកលេង សុំពូមកលេងស្រុកអីទេ អត់មានទេ?

ថៃវ ៖ សុំៗ មានសុំ ខ្មែរក្រហមក៏មានសុំ ប៉ាវ៉ាក៏មានសុំ ខ្ញុំជួយច្រើនណាស់ ។

ធានី ៖ ជួយចឹងដែរ?

ថៃវ ៖ មានសំបុត្រយើង សំបុត្រលិខិតអញ្ជើញយើង លិខិតធ្វើដំណើរ ដូច្នេះយើងមានត្រាបោះ តែខាងក្នុងឃើញមានលិខិតត្រឹមត្រូវហើយ អត់អីទេ គេថាយើងដាក់តែស្រុកស្រែនេះទៅ ។

ធានី ៖ ចុះម៉េចបានពូធ្វើតែម៉ាឆ្នាំ ហើយឈប់ធ្វើចឹង?

ថៃវ ៖ គេរំដោះប៉ាវ៉ារំដោះៗដីនេះចូលដីរំដោះ ។

ធានី ៖ រំដោះចូលរំដោះខាងណា ខាងខ្មែរក្រហម?

ថៃវ ៖ ប៉ាវ៉ាៗអត់បានដីស្រុកកាន់កាប់ទាំងអស់ ខ្ញុំគេជ្រើសប៉ាវ៉ាគេជ្រើសអ្នកផ្សេងគេ អ្នករបស់គេ ផ្សេងគេ ។

ធានី ៖ អូ! ចឹងពូឈប់?

ថៃវ ៖ ខ្ញុំឈប់ ខ្ញុំដើរធ្វើជាងផ្ទះជាងអី ។

ធានី ៖ ប៉ាវ៉ាខាងណាវិញ?

ថៃវ ៖ ប៉ាវ៉ាយើងនៅខាងសីនសាន ក៏លោកយើងសព្វថ្ងៃចូលខាងរដ្ឋកម្ពុជាវិញហើយ ។ តាហេង សួ ចាន់ហេង ។

ធានី ៖ សួ ចាន់ហេង ប្រធាន?

ថៃវ ៖ បាទ! ប្រធានកងពល ។

ធានី ៖ កងពលលេខប៉ុន្មាន ពូដឹងទេ?

ថៃវ ៖ កងពលលេខ៧ ។

ធានី ៖ លេខ៧?

ថៃវ ៖ បាទ! គេរើសៗតាមខ្សែគេ រើសមេភូមិរើសនគរបាល រើសមេឃុំរើសតាមខ្សែគេ ។

ធានី ៖ ចឹងពូឈប់ធ្វើទៅ ដល់ពេលឆ្នាំ៩១ដែលពូថាធ្វើជាផងដុះ ជាងអី?

ថៃវ ៖ បាទៗ ។

ធានី ៖ រហូតដល់?

ថៃវ ៖ ឆ្នាំ២០០២ ខ្ញុំចូលបេក្ខជនបោះឆ្នោតជាប់ជាក្រុមប្រឹក្សាឃុំ ។

ធានី ៖ ហើយដូចថាមើលរឿងរ៉ាវពូឆ្លងច្រើន សង្គ្រាមដងអីដងចឹង?

ថៃវ ៖ បាទ! ច្រើន វេទនា ។

ធានី ៖ ចឹងចង់សួរចិត្តពូថា តើពូយល់ថាម៉េចដែរ ចំពោះការរស់នៅពីមុនហើយឥឡូវ តើការរស់នៅខុសគ្នាយ៉ាងម៉េច ពីរបបទៅម៉ារបប?

ថៃវ ៖ បើការរស់នៅពីឆ្លងកាត់ដែលខ្ញុំរស់ ម៉ាកើតជីវិតខ្ញុំមកតាំងពីសម័យរាជានិយមឆ្នាំ៦៨ ៦៣ ៦៤ ៦៥ មក ដែលរស់ពីកុមារភាពមក សម័យរាជានិយម ក៏មិនបានធៀបនឹងសម័យនេះ ៦៨ រហូតឆ្លងកាត់របបប៉ុលពត ក៏ជារបបផ្ដាច់ការដែលយើងគួរឲ្យឈឺចាប់រហូតដល់សព្វថ្ងៃ នេះ ប្រើមនុស្សសម្លាប់មនុស្ស ដូចថាមិនឲ្យមនុស្សបានរស់ នេះក៏យើងបានឆ្លងកាត់ពីការស្លាប់រហូតបានផុតពីការស្លាប់បានរស់ ហើយឆ្លងមកវ៉ៃសម័យប៉ាវ៉ា សម័យរដ្ឋកម្ពុជា ក៏របប នោះ របបប្រទាញប្រទុង គឺកើតម៉ាថ្ងៃ ហើយមិនដឹងជាស្លាប់ថ្ងៃណា វ៉ៃគ្នារាល់ថ្ងៃ ច្បាំងគ្នា រាល់ថ្ងៃកន្លែងនេះសមរភូមិ បើមិនប៉ាវ៉ាមកវ៉ៃ វាវ៉ៃគ្នារាល់ថ្ងៃ ។ ដូច្នេះគឺ មិនផុតពីសេចក្ដី ស្លាប់ដែលចាំមើលមុខយើង រហូតដល់សព្វថ្ងៃ រហូតដល់ពេលយើងរំដោះដល់ឆ្នាំ៩៣ យើង បានធ្វើសមាហរណកម្មអីទាំងអស់ ។ បើគិតទៅយើងចាប់បានមកសួរចាប់ពីឆ្នាំ ៩៧ ៩៨ ដែលស្រួល ស្ងាត់សូរកាំភ្លើងជ្រាបៗ ដែលយើងបានរស់ដែលសុខសាន្ត ។ មានតែសម័យ នេះទេ ដែលរស់ស្រួលបំផុត

ដេកស្រួលបំផុត ដែលគ្មានអារម្មណ៍មួយដែលខ្លាច ថាមានគាំ ភ្លើងមកបាញ់យើងបាន ។ បើសម័យមុនៗគឺយើងឆ្ងល់ផុតៗ ស្អែកឡើងឆ្ងល់ ។

ធានី : ភ័យទៀត?

ថៃវ : ឆ្ងល់ម៉ាភ័យម៉ាថ្ងៃទៀត ឆ្ងល់ផុតថ្ងៃនេះ ស្អែកឡើងភ័យទៀត យើងគិតសេចក្តីស្លាប់ជាង ។ ឥឡូវនេះ គឺយើងគិតមានអី កុំតែយើងទៅលួចគេសព្វថ្ងៃ ថាកុំទៅលួចគេល្អ បើបានប៉ុននេះ ខ្ញុំយក ហើយក៏ពេញចិត្តហ្នឹងការរស់ ។

ធានី : ចឹងពូដែលធ្លាប់ឮរឿងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម?

ថៃវ : ទេ! មិនសូវជាបានដឹង ។

ធានី : តែបានដឹងថាមានគេកាត់ដែរ?

ថៃវ : ដឹងដែរ ដឹងថាគេកាត់ដែរ ។

ធានី : លោកពូពេញចិត្តនឹងតុលាការហ្នឹងទេ?

ថៃវ : ខ្ញុំពេញចិត្តណាស់ ។

ធានី : យល់ថាតុលាការយ៉ាងម៉េច?

ថៃវ : ព្រោះតុលាការយុត្តិធម៌ ព្រោះកាត់ទោសហ្នឹងដោយ បើសិនជាកាត់ទោសជនដែលបានធ្វើឲ្យខុស ធ្វើឲ្យដែលសង្គមស្អប់ខ្ពើម ជនដែលដឹកនាំនោះគឺសូមឲ្យមានទោសផង ហើយកាត់ទោសៗនោះតិចតួចផង បើគិតទៅកាត់ទោសវាតិចតួច វាដូចថាមិនទាន់ឆ្នាំ ដែលដាក់ឲ្យច្រើនឆ្នាំទៅ ។ ព្រោះបើវាគួរតែគិតឃើញដូចខ្ញុំ ខ្ញុំខ្មែរដែរប៉ុន្តែខ្ញុំឲ្យគេរស់ ដឹងថាមានបាយឲ្យរស់ ។

ធានី : ដូចថាពូធ្លាប់ឆ្ងល់កាត់សម័យខ្មែរក្រហមដូចថាធ្វើប្រធានយុវជនក៏ពូ?

ថៃវ : ខ្ញុំមិនដែលបានធ្វើចុះទេ មិនដែលបានធ្វើឲ្យបងប្អូនអត់ សួរមិត្តនារីៗ មានតែនារីៗទេមកសុំ ខ្ញុំដេរខោដេរអាវ ខ្ញុំឲ្យសិទ្ធិឲ្យសេរីភាព បើសិនជាថាមកសុំខ្ញុំដេរខោដេរអាវមានមិនដែល ហ៊ានសុំមេ....គេទេ.... អត់ហ៊ានឲ្យឈប់ទេ ខ្ញុំឲ្យឈប់ ក្មេងៗនៅភូមិ ។ ក្មេងៗអាយុកាល ដែលខ្ញុំជាមេគេទៅ ខ្ញុំអាយុច្រើនទៅ អាយុជិត២០ទៅ យក១៥ ១៣ ១៤ចូលចល័ត ហើយហៅចូលនារីហើយកាលនោះ អត់មានដូចពេញវ័យធ្វើចល័តទេ ចាប់ពី១៣ ១៤គឺចូល ចល័តហើយហៅកងចល័តហើយ ចូលយុវជនយុវនារីហើយ គេអាចបញ្ចូលកុមារ ។ ដល់ ពេលនោះហើយ គឺនារីពេញចិត្តខ្ញុំណាស់ សូម្បីតែគេរៀបបានលួចដាពងទាពងមាន់តែយក មកចែកខ្ញុំស៊ី ។

ពេលដែលខ្ញុំនាំកម្លាំងទៅបិទទំនប់ ពេលខ្ញុំទៅមិនឲ្យបង្គំនារីទេ ព្រោះនារីដែល មានកម្លាំងតិច ខ្ញុំដាក់ម៉ាប្រឡោះ៣ នារីដែលមានកម្លាំងធំដាក់ម៉ាប្រឡោះ២ ។

ធានី : មើលតាមកម្លាំងនារី?

ថែវ : បាទ! មើលតាមកម្លាំង ។

ធានី : តែចឹងខាងពូគ្រប់គ្រងទាំងយុវជន ឬក៏ទាំងនារី យុវជន?

ថែវ : ខ្ញុំៗមើលទាំង ពិតមែនតែខ្ញុំក្តាប់យុវជនមែន ក៏ខ្ញុំមើលបានទាំងអស់ព្រោះអំណាចអាឡែម នេះឲ្យខ្ញុំមើលទាំងអស់ ។

ធានី : ចឹងពូធំជាងមីងហួនហ្នឹងទៀត?

ថែវ : បាទ! ធំជាង ។

ធានី : ចឹងអ្នកណាម្នាក់ទៀត ខាងក្តាប់បុរស?

ថែវ : បុរសមានមេគេមហាជនគេមានផ្សេង ។

ធានី : ហ្នឹងមួយទៀតឈ្មោះអ៊ីគេ មួយស្មើនឹងមីងហួន ព្រោះអ៊ីពូធំជាងគេ បន្ទាប់មកមីងហួនៗ ហើយអ្នកណាម្នាក់ទៀត ដែលគេគ្រប់គ្រងដូចមីងហួនដែរ ខាងយុវជន?

ថែវ : គ្រប់គ្រងនេះ យុវជនសព្វថ្ងៃទៅ....បាត់ហើយ ។

ធានី : ឈ្មោះអ៊ីគេ?

ថែវ : ឆុយៗ ដែលនោះហ្នឹងមិនមែនទេ ។

ធានី : ឆុយ ដែលពូនោះហ្នឹងមិនមែនទេ?

ថែវ : ទេ!

ធានី : ពូហ្នឹងអ្នកណាគេវិញ?

ថែវ : ឆុយ នេះដែលគាត់ឡើង ដែលគាត់នេះឡើងក្រោយខ្ញុំទេ ។

ធានី : អូ! ជំនួសពូវិញ?

ថែវ : ដែលខ្ញុំទៅចល័តគេរើមេភូមិថ្មីទៀត អឺ!រើសយុវជនថ្មីទៀត ខ្ញុំនាំកងចល័តទៅម៉ាចំនួន ។

ធានី : ពេលដែលពូទៅកងចល័តទៅទំនប់ហ្នឹងបានគេ?

ថែវ : បាទ! បានគេអ្នករៀបចំក្រោយទៀត ។

ធានី : ចឹងកងចល័តរបស់ពូនៅខាងយុវជននៅក្នុងភូមិផ្សេង ដល់ពេលទៅលើទំនប់ការដ្ឋានផ្សេង?

ថែវ : បាទ! ខ្ញុំដល់ពេលបានអាកម្លាំងធំដែលគេកម្លាំងមហាជនដែលពេញកម្លាំង គេយកអាយុពេញ ដល់អាយុតូច អាយុមិនទាន់គ្រប់នៅនេះ អាកម្លាំងចាប់ពី១៥ឡើងទៅនោះ ។

ធានី ៖ ចឹងពូនៅខាងកម្មាំងធំ នៅខាងពេលលើកទំនប់នៅត្រពាំងថ្មហ្នឹងទេ ដែលថាក្ដាប់រួមធំបន្ទាប់ពីមីងហួន ពូហើយបានមីងហួន?

ថៃវ ៖ បាទៗ ។

ធានី ៖ ចឹងពូក្ដាប់ប៉ុន្មាននាក់ទៅកម្មាំងខាងត្រពាំងថ្មនោះ?

ថៃវ ៖ កម្មាំងត្រពាំងថ្មកាលនោះទៅវា កាលដក បើដកពីកម្មាំងអ្នកខ្លះ បើខ្ញុំទៅប្រហែលជា៦០ជាង ៦០នាក់ជាង ។

ធានី ៖ ៦០នាក់?

ថៃវ ៖ បាទ! បើគិតតាំងពីនេះ១០០ ។

ធានី ៖ ១០០នាក់ដដែល ព្រោះកាលមុនពូថានៅភូមិ១០០ដែរ?

ថៃវ ៖ អានោះ១០០ ។

ធានី ៖ ១០០ទាំងកូនក្មេង?

ថៃវ ៖ ១០០ៗតែប្រុស ។

ធានី ៖ ១០០តែប្រុស?

ថៃវ ៖ បាទ! ស្រីផ្សេង ។

ធានី ៖ ចា៎! ដល់ពេលលើកនេះទាំងស្រីទាំងប្រុស?

ថៃវ ៖ លើកនេះគេចំរាញ់ទៅប្រហែល១០០ៗជាង ។

ធានី ៖ ១០០ហ្នឹង ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ថៃវ ៖ ១០០កាលនោះប្រុសច្រើនជាងស្រី បើខ្ញុំថាប្រុសប្រហែលជា៦០ ។

ធានី ៖ ស្រី៤០?

ថៃវ ៖ ៤០ ។

ធានី ៖ ចឹងដូចថាចំពោះពូធ្លាប់ដូចថាក្នុងនាមជាអ្នកដឹកនាំម្នាក់ដែល តែជាអ្នកដឹកនាំកូនក្រុមតូចៗក្នុងការធ្វើការដ្ឋានតាមគេចឹង តើចំពោះចិត្តពូផ្ទាល់ពូយល់ថាតុលាការហ្នឹងយ៉ាងម៉េចដែរ ចំពោះការកាត់ទោសទៅលើមេដឹកនាំជាន់ខ្ពស់របស់សម័យខ្មែរក្រហមចឹង?

ថៃវ ៖ ទេ! អារឿងការកាត់ទោសខ្មែរក្រហម កាត់តុលាការជាន់ខ្ពស់ទើបត្រូវ ព្រោះបញ្ជាចេញពីលើមក អ្នកក្រោមអ្នកអត់ដឹងអីទេ ធ្វើតាមបញ្ជាអ្នកលើ ។

ធានី ៖ ចុះពូដែលធ្លាប់ប្រកែកបញ្ជាគេ អត់ឲ្យធ្វើកុំធ្វើចឹង ដែលធ្លាប់ទេ?

ថែវ : អត់ហ៊ានប្រឆាំងហ្នឹងគេទេ បើថាគេនាំឲ្យនាំតាមកម្លាំងថា អ្នកឯងត្រូវបិទទំនប់នេះម៉ាខែ្សធ្វើម៉េចគេកំណត់ក្នុងម៉ាអាទិត្យឲ្យរួច ឬក៏បិទផ្លូវ បិទភ្លឺស្រែប្រព័ន្ធភ្លឺក្នុងម៉ាខែ្សនេះ៣គីឡូឬ៥គីឡូ គេកំណត់ៗផែនការ គេដាក់ផែនការថាប្ដេជ្ញាថាធ្វើម៉េចឲ្យបានម៉ាអាទិត្យឲ្យរួចយើងត្រូវខំធ្វើ ។

ធានី : ធ្វើទាំងអស់គ្នា?

ថែវ : បាទ! ធ្វើ ។

ធានី : ពូធ្វើដែរ?

ថែវ : បាទ! ធ្វើ ដូច្នេះយើងត្រូវប្រជុំជីវភាព ប្រាប់គេថាយើង មិត្តយើងទាំងអស់គ្នា យើងធ្វើដើម្បីបំពេញបំណងអង្គការ គឺអង្គការបានចាត់តាំងឲ្យយើង ដាក់ផែនការឲ្យយើងក្នុងម៉ាខែ្សហ្នឹង គឺម៉ាអាទិត្យឲ្យចប់ ។ ដូច្នេះយើងទាំងអស់គ្នា ត្រូវខំទាំងអស់គ្នា ។

ធានី : ដែលធ្លាប់មានអ្នកក្នុងកម្លាំងរបស់ពូឈឺអីចឹង ហើយអត់?

ថែវ : ឈឺ ខ្ញុំឲ្យសម្រាក ។

ធានី : ចុះមានបានបាយហូបអត់ចុះ?

ថែវ : បាយហូប កាលឆ្នាំដែលខ្ញុំនៅអត់ទាន់តឹងទេ នៅបាយ ។

ធានី : បានហូបបាយ?

ថែវ : បាទៗ បានហូបគ្រប់គ្រាន់ កាលនោះគេបើកស្រូវហូប ឲ្យដាំ ។

ធានី : អូ! ដាំខ្លួនឯង?

ថែវ : បាទ! ដាំតាមគ្រួសារ មានជម្រករួមមួយ ។

ធានី : បើកស្រូវប៉ុន្មាន?

ថែវ : បើកស្រូវគេកំណត់ៗតាមមាត់ហូប ។

ធានី : ដូចថាម៉ាគ្រួសារប៉ុន្មាន?

ថែវ : បើស្រូវកំណត់ៗតាមមាត់ហូប ដូចថាម៉ាគ្រួសារខ្ញុំ ក្នុងបន្ទុកគ្រួសារខ្ញុំ៣-៤នាក់ចឹង គេឲ្យម៉ាដល់ៗហើយ គេកំណត់ឲ្យយើង គេប៉ាន់ឲ្យយើង ។

ធានី : ម៉ាកំប៉ុងអីពូដឹងទេ?

ថែវ : គេឲ្យជាស្រូវ ។

ធានី : ស្រូវហ្នឹងប៉ុន្មាន?

ថែវ : ស្រូវយកទៅកិន ។

ធានី ៖ ស្រូវប៉ុន្មាន?

ថៃវ ៖ ស្រូវយើងក្នុងម៉ាថ្ងៃ ។

ធានី ៖ គេឲ្យប៉ុន្មាន?

ថៃវ ៖ ខ្ញុំដូចភ្លេចបាត់ហើយកាលនោះ គេឲ្យខ្ញុំនៅក្នុងបន្ទុកម៉ែខ្ញុំដែរ ម៉ែខ្ញុំទៅបើកស្រូវបើកអី កាលនោះខ្ញុំនៅយុវជនខ្ញុំនៅក្នុងបន្ទុកម៉ែ ។

ធានី ៖ ចាំ! ព្រោះពូប្រធាន?

ថៃវ ៖ បាទៗ ។

ធានី ៖ ចឹងខាងយុវជនអីហ្នឹង ក៏គេឲ្យតាមផ្ទះ រៀងខ្លួនដូចគ្នា?

ថៃវ ៖ បាទ! រៀងខ្លួនដូចគ្នា ។

ធានី ៖ ដល់ពេលធ្វើការទៅជុំគ្នា?

ថៃវ ៖ បាទ! រៀងខ្លួនដូចគ្នា ហើយខ្ញុំមិនសូវបានបាយកញ្ចប់ទេ ស៊ីជិតនារី នារីដែលស្រួលជាមួយខ្ញុំ លោកបងហ៎ លោកបងហូបបាយជាមួយខ្ញុំ ស៊ីជុំនារីទៅ ។

ធានី ៖ ចឹងចង់សួរពូថា ក្នុងសម័យខ្មែរក្រហមអីហ្នឹង តើពូធ្លាប់មានជួយអ្នកណាគេទេនៅក្នុងសម័យហ្នឹង ជួយឲ្យរួចជីវិត?

ថៃវ ៖ ខ្ញុំជួយមួយដែរ ។

ធានី ៖ ឈ្មោះអីគេ?

ថៃវ ៖ ឈ្មោះ មីង ហុត ចាំមើលខ្ញុំនិយាយ អានេះគេខ្ញុំជួយដោយមិនបានដឹងខ្លួន ។ ថ្ងៃមួយនោះ គេឲ្យខ្ញុំ ឈ្លបឲ្យជិះសេះតាមខ្ញុំ ដែលខ្ញុំនិយាយមិញ ដល់អាអ៊ីម អាខាត់នឹង គេមានសៀវភៅក្រាំងមួយ បញ្ជីគេធំៗមកៗ ។ ខ្ញុំឃើញត្រសក់គេៗដាក់សហករណ៍គេ ទៅទុំត្រសក់គេដាក់សហករណ៍គេ ខ្ញុំទៅស៊ីទុំត្រសក់ ។ គេថាស៊ីមើលឲ្យស្អាត គេថាស៊ីមិត្តឯងស៊ីឲ្យល្អ ស៊ីមើលខ្លាចអ្នកស្រុកគេឃើញ ។ ខ្ញុំក៏ស៊ីលួចលាក់គៀនជញ្ជាំងគេ ដើរមកឆ្ងាយ ដល់ពេលស៊ីរួចមកៗមើលឈ្មោះ តាមក្រុមមិត្តឯងតើមានក្រុមត្រូវទៅជម្លៀសឬមិនមានទេ ។ ដល់ខ្ញុំមើលកូនក្រុមខ្ញុំមិនមានឈ្មោះ មិនមានឈ្មោះត្រូវទៅជម្លៀសទេ ។ ពិតហើយ ថាពិត ។ ដល់ខ្ញុំមើលទៅឈ្មោះមួយទៀត មើលឈ្មោះមួយ ត្រូវទៅជម្លៀស ឈ្មោះ មីង ហុត ត្រូវជាឪពុកមា ។

ធានី ៖ ឈ្មោះ មីង ហុត?

ថៃវ ៖ មីង ហុត ។

ធានី ៖ មីង ហុត?

ថែវ ៖ បាទ! ឈ្មោះត្រូវទៅជម្រើស

ធានី ៖ ម៉េចទៀតពូ?

ថែវ ៖ ដល់ឈ្មោះនេះគេដាក់ត្រូវទៅរៀនសូត្រ គេដាក់ថាជម្រើសទៅរៀនសូត្រ ។

ធានី ៖ ឈ្មោះហ្នឹងគេកត់ពីលើមកហើយ?

ថែវ ៖ គេកត់រួចហើយស្រេច តែគេគ្រាន់តែឲ្យយើងមើលទេ ។

ធានី ៖ ត្រូវអត់?

ថែវ ៖ បាទ! ត្រូវអត់ មានមិនមាន ដល់ខ្ញុំប្រកែកថាឈ្មោះនេះ ខ្ញុំសុំ វាប្រាប់ថាបើសិនជាឈ្មោះណាដែលគួរលុប វាប្រាប់ដែលហ្នឹង បើឈ្មោះណាដែលគួរលុប បើមិនមែនត្រូវទៅរៀនសូត្រ ដែលគួរលុប លុបទៅ តែបើឈ្មោះណាដែលមិនលុប កុំលុបរបស់គេ ។ ដល់ពេលហ្នឹងខ្ញុំមើលៗទៅ ដល់ពេលថ្ងៃដែលវាឲ្យយើងឈ្មោះ វាប្រាប់យើងត្រង់ ប្រាប់ថាមើលឈ្មោះណាដែលជាប់និន្នាការ ជាប់និន្នាការ ប្រវត្តិ បម្រើនិន្នាការសក្តិភូមិ ខ្ញុំដឹងៗបាត់ហើយ ដល់ៗខ្ញុំមើលឈ្មោះ មីង ហុត ។

ធានី ៖ គាត់ឈ្មោះ មីង?

ថែវ ៖ មីង ហុត ។

ធានី ៖ មីងរបស់ពូ?

ថែវ ៖ ឈ្មោះគាត់ ត្រកូលគាត់ ឪពុកឈ្មោះ មីង។ មីង នេះគឺត្រូវជីតាខ្ញុំ គាត់នេះត្រូវជាឪពុកមាបង្កើតខ្ញុំ ។ ដល់មើលឈ្មោះគាត់ ខ្ញុំនៅតាំងពីតូចមក គាត់មិនដែលឃើញគាត់ធ្វើអីទេ ។ ដូច្នេះ ខ្ញុំបានសុំប្រកែកថាខ្ញុំសុំលុបឈ្មោះនេះមួយ សុំគ្រីស(Tick) ឲ្យគ្រីស សុំគ្រីស(Tick ) ឈ្មោះនេះមួយ ។ ឈ្មោះនេះគេថា ម៉េចក៏គ្រីស អ្នកដឹងប្រវត្តិគាត់ទេ ។ ខ្ញុំថាដឹង ព្រោះខ្ញុំកើតមកក្នុងត្រកូលដែលខ្ញុំធ្លាប់ទៅបួសមក តាំងពីខ្ញុំតូចក្រូចឆ្មារមក ឈ្មោះ មីង ហុត នេះមិនដែលបានធ្វើការងាររអីទេ ធ្វើតែស្រែធម្មតា ។ ពិតណាស់ គេសួរខ្ញុំថាពិតណាស់ ។ ខ្ញុំថាពិត ។ បើពិត មិត្តឯងទទួលខុសត្រូវៗ បើសិនជាថ្ងៃក្រោយគេស្រាវជ្រាវថា មីងហុត នេះបានជាប់និន្នាការ មិត្តឯងទទួលខុសត្រូវ ។ ខ្ញុំថាអត់ដែរឃើញធ្វើអី ខ្ញុំហ៊ានលុប ព្រោះខ្ញុំកើតមកតាំងពីតូចគាត់មិនដែលធ្វើអីទេ ។ ដូច្នេះគឺខ្ញុំដឹងប្រវត្តិគាត់ ទាហានក៏មិនដែលធ្វើ មេភូមិក៏មិនដែលធ្វើ ប្រធានសហករណ៍ក៏មិនដែលអឺ! ប្រធានអា៥០ខ្នងក៏មិនដែលធ្វើ ។ ល្អលុបចុះ ។

ធានី ៖ តែមួយហ្នឹងទេ ពូ?

ចែវ ៖ មួយហ្នឹង ។

ធានី ៖ ចឹងរាល់ថ្ងៃ គាត់នៅរស់ទេ?

ចែវ ៖ នៅរស់ដល់សព្វថ្ងៃ ។

ធានី ៖ គាត់នៅខាងណាវិញ ពូដឹងទេ?

ចែវ ៖ នៅខាងចុងកើត ។

ធានី ៖ ភូមិអីដែរ?

ចែវ ៖ ភូមិស្វាយយើងនេះឯង ។

ធានី ៖ ភូមិស្វាយដែរ គាត់ឈ្មោះ មីង ហួត អីចឹងតែម៉ង?

ចែវ ៖ មីង ហុត ។

ធានី ៖ មីង ហុត?

ចែវ ៖ បាទ!

ធានី ៖ ហើយគាត់ដឹងទេ ពូ?

ចែវ ៖ អត់ដឹងថាខ្ញុំជួយ ប៉ុន្តែខ្ញុំប្រាប់កូនៗដែរ ថាអញបានលុបឈ្មោះឪឯង បានឯងរស់ដល់សព្វថ្ងៃ កុំអីឯងជម្លៀសងាប់អស់ហើយ ។

ធានី ៖ អីចឹងពូដឹងអ្នកផ្សេងទៀត ក្រៅពីហ្នឹងៗគឺគេសួរ?

ចែវ ៖ ខ្ញុំអត់ហ៊ានមើលរបស់គេទេ ព្រោះមើលទៅឃើញឈ្មោះសុទ្ធតែចំណុច ដែលគេត្រូវយើងមិនហ៊ានលុបរបស់គេទេ ឈ្មោះដែលមានប៉ុន្មាន៤០គ្រួសារសុទ្ធតែឈ្មោះដែរ ។

ធានី ៖ ដែលក្នុងចំណោម៤០ហ្នឹង ពូបានលុបរបស់ពូមួយ?

ចែវ ៖ លុបតែមួយ ។

ធានី ៖ អីចឹងក្រៅពីហ្នឹង៣៩?

ចែវ ៖ ៣៩ ពួកនោះសុទ្ធតែទាហាន ។

ធានី ៖ ហេតុអីបានជាគេសួរយោបល់ពីពូវិញ ពូដឹងទេ?

ចែវ ៖ ហ៎?

ធានី ៖ ហេតុអីបានជាអ្នក ឈ្មោះអីទេ?

ចែវ ៖ អាខាត់ អាអ៊ីម ។ ព្រោះយើងជាមេក្រុមបាយ ។

ធានី ៖ មេក្រុមបាយ?

ថែវ ៖   មេក្រុមបាយ  គេឲ្យយើងមក ។

ធានី ៖   គេមិនសួរខាងសន្តាត់ខាងអី  ម៉េចទៅសួរពូវិញ  ចង់និយាយអីចឹង?

ថែវ ៖   គេឲ្យមេក្រុមបាយនេះគេឲ្យមក  មេក្រុមយើង  គេឲ្យមកមើលឈ្មោះគ្រប់ក្រុម  មើលគ្រប់គ្នា បេះឯង ។

ធានី ៖   ចុះមេក្រុមក្រៅពីពូ?

ថែវ ៖   មេក្រុមមកគ្រប់គ្នាៗ ។

ធានី ៖   មេក្រុមអីទៀត  ពូមានស្គាល់ឈ្មោះគាត់ទេ?  អ្នកផ្សេងទៀតដែលជាមេក្រុម?

ថែវ ៖   មេក្រុមសព្វថ្ងៃ  នៅដឹងណាណានៅ  មេក្រុមឈ្មោះ  មើយ  នោះងាប់ហើយ ។

ធានី ៖   មេក្រុមបាយទីប៉ុន្មាន?

ថែវ ៖   មេក្រុម  មើយ  នោះមេក្រុមទី២ ។

ធានី ៖   ទី២ឈ្មោះ  មើយ?

ថែវ ៖   បាទ!

ធានី ៖   ស្លាប់ហើយ?

ថែវ ៖   បាទ!  មេក្រុម  យាន  នោះទី១  តាយានៗ ។

ធានី ៖   នៅរស់ទេ  ពូ?

ថែវ ៖   ងាប់ហើយ  តាយាន  ស្លាប់ហើយ ។

ធានី ៖   ស្លាប់ដែរ ។  ទៀតពូ?

ថែវ ៖   មេក្រុម  យើង  ជួយ  ទីប៉ុន្មានទេ ។

ធានី ៖   យើង  ចយ?

ថែវ ៖   ជួយ ។

ធានី ៖   យើង  ជួយ ។

ថែវ ៖   បងបង្កើត  របស់គាត់ ។

ធានី ៖   បងស្រី  បងប្រុស?

ថែវ ៖   បងប្រុស  គាត់មិនដឹងធ្វើប្រធានក្រុមទីប៉ុន្មាន?

ធានី ៖   គាត់នៅរស់ទេ?

ថែវ ៖   នៅរស់  តែសព្វថ្ងៃពិការហើយ  ឈឺជើង  ចាស់ ។

ធានី ៖   គាត់នៅភូមិយើងដែរ?

ថៃវ ៖ បាទ!

ធានី ៖ នៅភូមិស្វាយ ។ ហើយពីណាទៀត ពីព្រោះមាន៧ក្រុមទេ?

ថៃវ ៖ មិនមែន៧ទេ ។

ធានី ៖ ច្រើន ។

ថៃវ ៖ ដូចជា៨-៩ ពីព្រោះខ្ញុំក្រុមទី៧ ។

ធានី ៖ អីចឹង៨ក្រុម ចឹងពូ?

ថៃវ ៖ ទេ!៨-៩ ក្រុមទី៨ ហាច ។

ធានី ៖ ក្រុមទី៨ ហាច?

ថៃវ ៖ សួស ហាច ។

ធានី ៖ សួស ហាច ។ នៅរស់ទេ?

ថៃវ ៖ តាហាច ស្លាប់ហើយ ។

ធានី ៖ អ្នកផ្សេងទៀត?

ថៃវ ៖ ភ្លើយ ។

ធានី ៖ ទីប៉ុន្មានពូ?

ថៃវ ៖ ពិន ភ្លើយ ។

ធានី ៖ ពិន ភ្លើយ ទីប៉ុន្មាន?

ថៃវ ៖ ពិន ភ្លើយ ប្រហែលជាក្រុមទី៣ ។

ធានី ៖ ពិន ភ្លើយ ទី៣?

ថៃវ ៖ បាទ!

ធានី ៖ នៅរស់ទេ ពូ?

ថៃវ ៖ រស់ ។

ធានី ៖ នៅណាវិញ?

ថៃវ ៖ នៅចុងត្បូងនោះ ។

ធានី ៖ នៅភូមិយើងដែរ?

ថៃវ ៖ ភូមិយើងដែរ ។

ធានី ៖ ភូមិស្វាយដូចគ្នា ។

ថៃវ ៖ បាទ! ពិន ភ្លើយ ។

ធានី ៖ អ្នកណាទៀត ។

ថែវ ៖ នៅត្បូងខ្ញុំមកមិនបាននៅយូរប៉ុន្មានដែរ ខ្ញុំរត់ទៅថៃ ។

ធានី ៖ ព្រោះកាលហ្នឹង អ៊ឹមៗ?

ថែវ ៖ អ៊ឹម ប្រធានសហករណ៍ ។

ធានី ៖ ហ្នឹងហើយ អ៊ឹម ប្រធានសហករណ៍?

ថែវ ៖ បាទ! ប្រធានសហករណ៍រួម ប្រធានរួមម៉ាថ្នពួក ។

ធានី ៖ កាលហ្នឹងប្រធានសង្កាត់ ឬប្រធាន?

ថែវ ៖ ប្រធានសហករណ៍ កាលហ្នឹងគេហៅសហករណ៍ហើយ ។

ធានី ៖ សហករណ៍ និងសង្កាត់ មួយណាធំជាង?

ថែវ ៖ ពាក្យមុនដំបូងគេដាក់សង្កាត់ធំ ។

ធានី ៖ ដល់ក្រោយទៅ?

ថែវ ៖ បំបែកសហករណ៍ ខ្ញុំឆ្ងល់ដែរសហករណ៍ ។

ធានី ៖ អីចឹងសហករណ៍ធំជាងសង្កាត់ទៀត?

ថែវ ៖ ធំជាងសង្កាត់ វាក្ដាប់ធំណាស់ ។

ធានី ៖ ក្ដាប់មួយស្រុកថ្នពួកហ្នឹង?

ថែវ ៖ ទេ! មិនមែនទេ ។

ធានី ៖ ក្ដាប់ម៉ា?

ថែវ ៖ ក្ដាប់ម៉ាឃុំថ្នពួក បាទ! វាប្រែជាសហករណ៍ ដល់វាកើតដល់វាប្រែខ្ញុំក៏មិនដឹងន័យវាដែរ ។

ធានី ៖ ចឹង អ៊ឹម ហ្នឹងជាអ្នកដើរសួរៗ?

ថែវ ៖ អ៊ឹម ហ្នឹងជាអ្នកឲ្យយើងមកមើលបញ្ជីឈ្មោះសមាជិកយើង ។

ធានី ៖ កាលពូមើល មើលតែម្នាក់ឯងទេ អត់មានអ្នកផ្សេងទេ?

ថែវ ៖ គេឲ្យមើលមុនៗម៉ាៗនាក់ ។

ធានី ៖ វៀងៗខ្លួន?

ថែវ ៖ ឧបមាថានាងឯងក្រុមទី៨ មើលក្រុមទី៨មុនទៅ មើលផុតតែក្រុមឯងមានអីទេ បើក្រុមឯងមានដើរទៅប្រាប់គេប្រាប់ទៅសមាជិកយើង ឲ្យរៀបចំរទេះគោរទៅរៀនសូត្រ ។

ធានី ៖ ចឹងចង់សួរពូថា កាលពេលពូមើលហ្នឹង មានមើលប៉ះក្រុមគេ មានអ្នកស្គាល់ទេ?

ថែវ ៖ ប៉ះក្រុមគេ ដែលថា មីង ហុត ហ្នឹងក្រុមគេតើ មិនមែនក្រុមខ្ញុំទេ ។

ធានី ៖ ហើយចឹងចង់សួរពូថា តើពូមើលទាំងអស់នឹង តើពូមានស្គាល់អ្នកផ្សេងទៀតទេ ដែលពូដឹងថាគាត់ត្រូវគេយកទៅសម្លាប់អីចឹង មើលហើយមានស្គាល់ទេ?

ថែវ ៖ មើលហើយតែមិនហ៊ានគ្រីស(Tick) ទេ ។

ធានី ៖ តែមានៗស្គាល់ទេ?

ថែវ ៖ មានស្គាល់ដែរ ។

ធានី ៖ ប៉ុន្មាននាក់ដែលពូ ច្រើនទេ?

ថែវ ៖ ច្រើនណាស់ ដែលត្រូវជម្លៀស មើលតាំងពីតាណក់ អូយ!ច្រើនណាស់ វា៣០-៤០មិន ដែលសិក្សាចាំ ។

ធានី ៖ ពូអាចចាំឈ្មោះ ជួយរៀបរាប់បន្តិចបានទេ?

ថែវ ៖ ចុះៗទៅបាត់ហើយនាង ។

ធានី ៖ ចុះ?

ថែវ ៖ ច្រើនមិនបានទេ ប្រាប់ត្រង់ ។

ធានី ៖ ប្រាប់គាត់ឲ្យគាត់ចុះហើយ ចុះឈ្មោះដែលពួកខ្ញុំឲ្យចុះ ។

ថែវ ៖ ដែលជម្លៀស ដែលគេយកទៅវៃចោល ។

ធានី ៖ ប្រាប់គាត់អស់ហើយ?

ថែវ ៖ ប្រាប់អស់ហើយ ។

ធានី ៖ ហើយមានធ្វើអី មុខងារអីមានទេពូ?

ថែវ ៖ ដឹងតែគេជម្លៀសយកទៅវៃចោល ព្រោះប្រវត្តិគាត់ទាហាន លន់ នល់ ។

ធានី ៖ ចង់ឲ្យចេះ ចង់ឲ្យពូជួយប្រាប់ថា ឧទាហរណ៍ថាឈ្មោះអីគេ ឈ្មោះ"ក" ប្រុស ឬស្រី គាត់ជាអីនឹងពូ ហើយគេជម្លៀសទៅណា ហេតុអីបានគេជម្លៀសគាត់ចឹង ហេតុអីបានគេយកទៅ?

ថែវ ៖ មានមេភូមិ ។

ធានី ៖ ឈ្មោះអីគេពូ?

ថែវ ៖ ប្រវត្តិដែលត្រូវមានខ្វះជាប់និន្នាការសេម័យ លន់ នល់ ។

ធានី ៖ ឈ្មោះអីគេ ពូចាំចង់ឲ្យពូរៀបរាប់?

ថែវ ៖ ឈ្មោះនៅនោះ ឲ្យឈ្មោះមក ។

ធានី ៖ ចាំ! ចឹងដូចថាខ្ញុំអត់ដឹងមានអីចង់សួរពូទៀត ពូមានអីចង់សួរខ្ញុំវិញទេ ពូចង់សំណូមពរ ឬក៏ចង់?

ថៃវ ៖ ដូចខ្ញុំសួរចេះ សុំឲ្យប្អូនស្រីដែលសុំឲ្យមកអ្នកសម្របសម្រួលការសម្ភាសន៍នេះ ហើយសុំឲ្យការកាត់ទោសរបស់ថ្នាក់ដឹកនាំកំពូលនេះ គឺសុំឲ្យកាត់ទោសកុំឲ្យបន្ធូរដៃ ដូចថា ខៀវ សំផនក៏អ្នកដើមចមដែរ ។

ធានី ៖ ពូស្គាល់គាត់ដែរ?

ថៃវ ៖ ហេ! ស្គាល់តែតាមប៉ុស្តិ៍ ។

ធានី ៖ កាលសម័យហ្នឹងអត់ដែលឃើញទេ?

ថៃវ ៖ អត់ដែលឃើញទេ បើឃើញតែ រស់ ញឹម ឃើញ ។

ធានី ៖ រស់ ញឹម ឃើញគាត់មក?

ថៃវ ៖ ឃើញគាត់មកមើលការដ្ឋាន ហើយយកសិល្បៈមកលេង ហើយគាត់ក៏បាននិយាយសមាជអន្តមេទិញ ហើយនិង ជៀល ប្អូនអី!កូនតាញឹម ។

ធានី ៖ កូនគាត់?

ថៃវ ៖ កូនគាត់ ហ្នឹងឃើញផ្ទាល់ភ្នែកតែម្តង ។

ធានី ៖ ជៀល ហ្នឹងគណៈ?

ថៃវ ៖ គណៈតំបន់៥ ។

ធានី ៖ គណៈតំបន់៥ហ្នឹង?

ថៃវ ៖ ចាប់ ហ៊ីង ចាប់អី ឡើង ជៀលហ្នឹង ។

ធានី ៖ អីចឹងពូប្រាប់ថាចាប់ ឆាត, អៀង ឡៃ អី ក្រែងថា ឆាត?

ថៃវ ៖ ហ្នឹងហើយ ឡើង ជៀល ប៉ុនឡើង ជៀល មិនបានយូរ ។

ធានី ៖ ហ៊ីង១ចុះហ៊ីង?

ថៃវ ៖ ហ៊ីង ចាប់មុន ។

ធានី ៖ ចាប់ ហ៊ីង ហើយបាន?

ថៃវ ៖ ឆាត ។

ធានី ៖ ឆាត១ ហើយ អៀង ឡៃ១ ហើយបានឡើង ជៀល?

ថៃវ ៖ បាទ! ឡើង ជៀល នោះឯង ។

ធានី ៖ ហើយ ជៀលហ្នឹងឡើងឆ្នាំប៉ុន្មានពូចាំទេ?

ប៉ែវ :   ជៀល ឡើងក្នុងអែបៗគ្នាហ្នឹង ឡើងមិនបានយូរទេ គ្រាន់តែឡើងបានបន្តិច អាសឿន ចូល សឿន ចាប់ ជៀល ទៀត។

ធានី :   សឿន, សៀវ អី?

ប៉ែវ :   សៀវ ខាងស្រុកទេ ខាងឃុំទេ។

ធានី :   ចុះខាងតំបន់អ្នកណាគេវិញ?

ប៉ែវ :   តំបន់ដូចខ្ញុំថា ហ៊ឹង, ឆាត, ឈ្មោះ ហុប ពាយ័ព្យ។ ហ៊ឹង, ឆាត, អឺ!

ធានី :   អៀង ឡៃ?

ប៉ែវ :   អៀង ឡៃ។

ធានី :   ហើយបានជៀល?

ប៉ែវ :   អឺ!បើខាងស្រុកវិញ ឆាតៗ គណៈស្រុក។

ធានី :   អូ! ឆាតស្រុកទេ?

ប៉ែវ :   គណៈស្រុក ។

ធានី :   ដល់ពេលហ៊ឹង, អៀង ឡៃ គេចាប់?

ប៉ែវ :   ហ្នឹងហៅខាងតំបន់ហើយ ប្រធានតំបន់។

ធានី :   ដល់គេចាប់ហើយបានចូល តាយ៉ុន អី តាយុន ប្រធានការដ្ឋាន?

ប៉ែវ :   តាយ៉ុយ ប្រធានការដ្ឋាន។

ធានី :   សៀន ប្រធានថ្នួក?

ប៉ែវ :   អាសឿនៗនេះ ហើយពួកខាងនិរតី។

ធានី :   សឿន គាត់ខាងនិរតី តែគាត់ខាងត្រពាំងថ្មទេ?

ប៉ែវ :   បាទ!

ធានី :   គណៈតំបន់?

ប៉ែវ :   គណៈតំបន់ តាប់ នោះឯងតំបន់។ ចាំមើលចាប់នោះបានឡើង ជៀល នោះឯងខ្ញុំអត់ បាន ប្រាប់រឿង ជៀល ទេ។

ធានី :   ចាំ! អត់បានប្រាប់ទេ។

ប៉ែវ :   អត់បានប្រាប់ ជៀល។

ធានី :   អីចឹងបានន័យថាចាប់ ហ៊ុង ហើយ អៀង ឡៃ ហើយបាន?

ថែវ ៖ ជៀល ឡើងហើយ អាសឿន មួយអែបអត់ទាន់ចាប់ទេ មិនទាន់ចាប់ ជៀល គ្រាន់តែមក អែបសំណែបធម្មតា ។

ធានី ៖ ជាមួយ សឿន?

ថែវ ៖ បាទ!

ធានី ៖ សឿន នីរតីហ្នឹងពូ?

ថែវ ៖ បាទ! នីរតី សឿន ។

ធានី ៖ ដល់បន្ទាប់មកទៀតចាប់ ជៀល ហើយបាន សឿន ឡើងពេញសិទ្ធិ?

ថែវ ៖ បាទ! សឿន ឡើងពេញសិទ្ធនោះឯង ។

ធានី ៖ យល់ហើយ ព្រោះមិញពូអត់និយាយរឿង ជៀល ទេ?

ថែវ ៖ ខ្ញុំភ្លេច ជៀល ។

ធានី ៖ អីចឹង ជៀល ហ្នឹងឡើងបានប៉ុន្មានខែបាន សឿន?

ថែវ ៖ បើតាម ជៀល មិនបានកន្លះឆ្នាំទេ មិនបាន៣-៤ខែផងបាត់ ជៀល ទៀត ។

ធានី ៖ ជាល ថាកន្លះឆ្នាំចុះពូ?

ថែវ ៖ បាទ!

ធានី ៖ ឆ្នាំប៉ុន្មាន ឆ្នាំជិត?

ថែវ ៖ ក្នុងឆ្នាំ៧៦-៧៧ ។

ធានី ៖ ៧៧ ឬ៧៨?

ថែវ ៖ ដល់ចុង៧៦ ជិតចូល៧៧ ។

ធានី ៖ ព្រោះពូថាចុង៧៦-៧៧ចាប់ ហឹង ។

ថែវ ៖ បន្តបន្ទាប់គ្នា នៅជិតៗគ្នា មើលតែខ្ញុំថា ។

ធានី ៖ អីចឹងដើម៧៧បាន ជាល ឡើង ។

ថែវ ៖ ជៀល ឡើង!

ធានី ៖ ជៀល ឡើងបានរយៈពេលកន្លះឆ្នាំ បាន សឿន ឆ្នាំ១៩៧៧ ពាក់កណ្ដាលឆ្នាំហ្នឹងទៅ?

ថែវ ៖ បាទៗ ។

ធានី ៖ គណៈតំបន់៥ ?

ថែវ ៖ បាទ!

ធានី ៖ បន្តទៀតម៉េចទៀតពូ សុំពូនិយាយ?

ថែវ ៖ សុំឲ្យតុលាការកាត់ទោសថ្នាក់ដឹកនាំ ដែលជាការប្រល័យពូជសាសន៍ជាតិឯង ពូជឯង សុំឲ្យកាត់ទោសកុំឲ្យបន្ធូរដៃ អ្នកទាំងនោះហើយជាអ្នកដើមចម គ្មានអ្នកណាមួយ នៅពីក្រោយខ្នងគឺអ្នកទាំងនោះហើយដែលបញ្ជាឲ្យសម្លាប់ខ្មែរគ្នាឯង ដូច្នេះការឈឺចាប់របស់ប្រជាពលរដ្ឋខ្មែរមិនទាន់បាត់ឈឺចាប់ទេ គឺឲ្យគាត់មានការសោកស្តាយ កូនចៅ ការសោកស្តាយម៉ែឪរបស់គាត់ នេះជាបណ្តាំរបស់ខ្ញុំ ដែលឲ្យនាងដែលនាំពាក្យនេះ សុំឲ្យខាងលើ ខាងតុលាការយកចិត្តទុកដាក់ កុំកាត់ៗតែមាត់ ទុកឲ្យអ្នកទាំងនោះបានរួចខ្លួន ។

ធានី ៖ អ៊ីចឹងពូអត់ស្គាល់មេដឹកនាំហ្នឹងកាលពីមុនទេ ស្គាល់តែ តាញឹម មួយទេ?

ថែវ ៖ បាទ! ស្គាល់តែ តាញឹម ។

ធានីៈ ចុះ ហង្ស ពិន ពូដែលលឺឈ្មោះទេ?

ថែវៈ ហង្ស អី?

ធានីៈ ហង្ស ពិន?

ថែវៈ មិនបានស្គាល់ទេ?

ធានីៈ ឌុច?

ថែវៈ មិនដែលស្គាល់ទេ ។ ប៉ុន្តែបើសិនជា តាឌុច មួយសារនោះនៅឆ្នាំនេះឯង ។

ធានីៈ ចា៎! នៅឆ្នាំ ។

ថែវៈ ប្រវត្តិគាត់ធ្វើគ្រូបង្រៀន ។

ធានីៈ អ៊ីចឹងអរគុណពូច្រើន បានផ្តល់បទសម្ភាសន៍ ។

«ចប់»